# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI00203**

## សម្ភាសន៍ជាមួយឈ្មោះ ធិប សំផាត់ ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ អ្នកទោសនៅគុកភ្នំទ្រយោង
## សព្វថ្ងៃរស់ភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា

០១:១៩:៣៥

៥០ទំព័រ

ដានី : ដំបូងខ្ញុំចង់ស្គាល់ឈ្មោះពេញរបស់លោកពូៗឈ្មោះអី?

សំផាត់ : ធិប សំផាត់ ។

ដានី : ធិប សំផាត់?

សំផាត់ : បាទ!

ដានី : លោកពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

សំផាត់ : ខ្ញុំឥឡូវអាយុ៥៨ហើយ ។

ដានី : អាយុ៥៨ឆ្នាំ ។ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

សំផាត់ : ចាន់ សាវ៉ឺ ។

ដានី : ចាន់ សាវ៉ឺ សរសេរយ៉ាងម៉េចទៅ ចាន់ សាវ៉ឺ?

សំផាត់ : ចាន់ សាវ៉ឺ ។

ដានី : ចាន់ សាវ៉ឺ គាត់អាយុប៉ុន្មានដែរ?

សំផាត់ : អាយុ៤៧ហើយ ។

ដានី : លោកពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

សំផាត់ : ៥នាក់ ។

ដានី : ៥នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សំផាត់ : ប្រុស២ ស្រី៣ ។

ដានី : លោកពូសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើស្អី?

សំផាត់ : នេះអារលក់ទឹកកកនេះ ធ្វើស្រែ ។

ដានី ៖ លក់ទឹកកក និងធ្វើស្រែ?

សំផាត់ ៖ បាទ!

ដានី ៖ លោកពូ ស្រុកកំណើតកើតជារបស់លោកពូនៅភូមិឃុំស្រុកអីដែរ?

សំផាត់ ៖ បាទ! នៅព្រះនេត្រព្រះ នៅភូមិកណ្ដាល ។

ដានី ៖ នៅភូមិកណ្ដាល ឃុំអីអានឹង?

សំផាត់ ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ បើនិយាយពីរឿងកំណើត ខេត្តបាត់ដំបងពីដើម បច្ចុប្បន្នបន្ទាយមានជ័យ ។

ដានី ៖ សព្វថ្ងៃពូរស់នៅភូមិឃុំអីដែរ?

សំផាត់ ៖ ភូមិ ។

ដានី ៖ សព្វថ្ងៃនឹងរស់នៅណា?

សំផាត់ ៖ ទៅមកៗ ។

ដានី ៖ ចឹងលោកពូដាក់អាស័យដ្ឋានមួយណាទៅ ក្នុងកន្លែងអត្តសញ្ញាណប័ណ្ណ?

សំផាត់ ៖ នៅព្រះនេត្រព្រះ ។

ដានី ៖ នៅភូមិអី?

សំផាត់ ៖ នៅភូមិឃុំដែលបានចុះហើយ ។

ដានី ៖ នៅភូមិកណ្ដាលដដែល?

សំផាត់ ៖ បាទ!

ដានី ៖ ភូមិកណ្ដាលដដែល ឃុំព្រះនេត្រព្រះដដែល?

សំផាត់ ៖ បាទ! អត់ទាន់មានកាត់ស្ទីមួយផង ។

ដានី ៖ តែឥឡូវនេះ ពូមកលក់ដូរមកលក់នៅភូមិអីដែរ?

សំផាត់ ៖ នៅភូមិកំពង់ស្វាយ ។

ដានី ៖ សព្វថ្ងៃនេះមកលក់ដូរនៅភូមិកំពង់ស្វាយ?

សំផាត់ ៖ បាទ!

ដានី ៖ ឃុំអីដែលអានឹង?

សំផាត់ ៖ នេះឃុំកំពង់ស្វាយដែរនឹង ក្រុងសេរីសោភ័ណ្ឌ ។

ដានី ៖ ឃុំកំពង់ស្វាយ ក្រុងសេរីសោភ័ណ្ឌ?

សំផាត់ ៖ បាទ!

ដានី ៖ លោកតូ ឪពុកលោកតូគាត់ឈ្មោះអីដែរ?

សំដាត់ ៖ អូ! គាត់ស្លាប់អស់ហើយ ។

ដានី ៖ ប៉ុនគាត់ឈ្មោះអីដែរ?

សំដាត់ ៖ ឪពុកឈ្មោះ ធិប ផន ។

ដានី ៖ ធិប ផន?

សំដាត់ ៖ បាទៗ ។

ដានី ៖ គាត់ស្លាប់តាំងពីអង្កាល់?

សំដាត់ ៖ ស្លាប់ឆ្នាំ៨៦ ។

ដានី ៖ ចុះម្ដាយ?

សំដាត់ ៖ ម្ដាយឈ្មោះ ឡាប ភួយ ។

ដានី ៖ ឡាប ភួយ?

សំដាត់ ៖ បាទ! អាហ្នឹងគាត់ស្លាប់តាំងពីសម័យប៉ុលពត ។

ដានី ៖ ចុះលោកតូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

សំដាត់ ៖ ៥នាក់ ។

ដានី ៖ បងប្អូន៥នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរ?

សំដាត់ ៖ ប្រុស២ ស្រី៣ ។

ដានី ៖ ចុះលោកតូកូនអីប៉ុន្មានទៅ?

សំដាត់ ៖ ខ្ញុំទី៣ ។

ដានី ៖ កាលពីក្មេងៗលោកតូបានរៀនសូត្រអីដល់ណា?

សំដាត់ ៖ ខ្ញុំរៀនដល់ថ្នាក់ទី៧ ។

ដានី ៖ ថ្នាក់ទី៧ រៀននៅណាទៅ?

សំដាត់ ៖ រៀននៅព្រះនេត្រព្រះ ។

ដានី ៖ ឈ្មោះអីសាលានឹង?

សំដាត់ ៖ សាលាឃុំព្រះនេត្រព្រះ ។

ដានី ៖ នៅក្នុងឃុំម៉ង តូ?

សំដាត់ ៖ បាទ! សាលាក្នុងឃុំព្រះនេត្រព្រះ ។

ដានី ៖ រៀនថ្នាក់ទី៧នឹង លោកតូឈប់រៀនឆ្នាំណាទៅ?

សំផាត់ ៖ ៧៤ ។

ដានី ៖ ឈប់រៀនហើយធ្វើអីទៀតទៅ?

សំផាត់ ៖ ធ្វើស្រែ ។

ដានី ៖ មូលហេតុអីបាន៧៤ឈប់រៀន?

សំផាត់ ៖ ទេ! មានមូលហេតុអី ធ្វើស្រែបណ្ដោយ ខ្ជិល ។

ដារ៉ា ៖ ឬក៏នៅក្នុងភូមិរបស់ពូពេលហ្នឹង មានខាងខ្មែរក្រហមខាងអីចូលដល់?

សំផាត់ ៖ អត់ទេ កាលនោះអត់ទាន់ដល់ទេ នៅព្រះនេត្រព្រះ វានៅតែឆ្ងាយៗ ។

ដានី ៖ ចឹងកាលហ្នឹង ពូឈប់រៀនមក ពូទៅជួយធ្វើស្រែឪពុកម្ដាយ?

សំផាត់ ៖ បាទ! ទៅជួយធ្វើស្រែឪពុក ។

ដានី ៖ ធ្វើស្រែរហូតដល់ពេលណាទៅ?

សំផាត់ ៖ ធ្វើដល់វគ្គអាពតចូល ។

ដានី ៖ ធ្វើស្រែរហូតដល់ ប៉ុល ពត ចូល?

សំផាត់ ៖ បាទ!

ដានី ៖ ប៉ុល ពត ចូលឆ្នាំណា?

សំផាត់ ៖ ឆ្នាំ៧៥ ។

ដានី ៖ ដល់ពេល ប៉ុល ពត ចូលឆ្នាំ៧៥យ៉ាងម៉េចទៀត ពូត្រូវធ្វើអីវិញ?

សំផាត់ ៖ នៅចល័ត ។

ដានី ៖ ពូអាចរៀបរាប់កន្លែងពេល ប៉ុល ពត ចូលមក ពូទៅចល័ត ពូត្រូវគេឲ្យធ្វើអីខ្លះ?

សំផាត់ ៖ នៅចល័ត គ្មានធ្វើស្អី មានតែរែកដីហ្នឹងឯង។ រែកដី លើកធ្វើទំនប់ធ្វើអី ធ្វើស្រែ ។ ទៅចល័តប្រហែលបានម៉ាឆ្នាំ គេដកឲ្យមកនៅភូមិវិញ ។ មកនៅភូមិវិញគេរើសពេទ្យៗឃុំ គេឲ្យខ្ញុំចូលទៅធ្វើពេទ្យឃុំ ចូលខាងពេទ្យគ្រូនចាញ់កាលនោះ ។

ដារ៉ា ៖ កាលនឹងឃុំអ្នកណាប្រធានឃុំប្រធានអី?

សំផាត់ ៖ អូ! មេឃុំស្លាប់អស់ហើយឈ្មោះ តាក្រុក ។

ដារ៉ា ៖ តាក្រុក ជំនាន់តាក្រុក?

សំផាត់ ៖ ឈ្មោះ តាក្រុក ។

ដារ៉ា ៖ ហើយមកធ្វើពេទ្យនឹង ដំបូងមានគ្នាច្រើនទេ មកចូលធ្វើពេទ្យ?

សំផាត់ ៖ ម៉ាភូមិកាលនោះគេយក៣នាក់ ។

ដារ៉ា ៖ ៣នាក់?

សំដាត់ ៖ បាទ!

ដារ៉ា ៖ ចឹងមានពូម្នាក់ដែរនៅក្នុងនឹង?

សំដាត់ ៖ បាទៗ ។

ដារ៉ា ៖ ចុះ២នាក់ទៀតពូស្គាល់ទេ?

សំដាត់ ៖ ២នាក់ទៀត អត់ដឹងទៅខាងណាទេ វាបែកគ្នាអស់ទៅ ។

ដារ៉ា ៖ តែពូស្គាល់ទេ ២នាក់ហ្នឹង?

សំដាត់ ៖ អ្នកភូមិជុំគ្នានឹង ។

ដារ៉ា ៖ ចឹង? ឈ្មោះអីខ្លះទៅពូ?

សំដាត់ ៖ អាមួយស្លាប់ហើយជំនាន់អាពត ដែលរត់ទៅ ជាមួយនៅឃុំប្រាសាទនោះ ។

ដារ៉ា ៖ ចុះមួយស្លាប់នឹងឈ្មោះអី?

សំដាត់ ៖ អានោះឈ្មោះវាអា សំរាន ។

ដារ៉ា ៖ ហើយចុះមួយនៅឃុំប្រាសាទនឹងឈ្មោះអី?

សំដាត់ ៖ អានឹងឈ្មោះ សែន ។

ដារ៉ា ៖ សំរាន, សែន ហើយនិងពូនឹង ចូលធ្វើពេទ្យឃុំជាមួយគ្នា?

សំដាត់ ៖ បាទៗ ។

ដារ៉ា ៖ កាលនឹងគេរើសៗរបៀបម៉េចពូ?

សំដាត់ ៖ គេរើសតាមភូមិឲ្យចូលទៅធ្វើពេទ្យឃុំទៅ ដល់ទៅកន្លែងឃុំបានគេបែងចែក ។ ទៅខ្ញុំផ្នែកខាងគ្រុនចាញ់ ។

ដារ៉ា ៖ ហើយដោយសារពូមានលក្ខណៈសម្បត្តិយ៉ាងម៉េច បានគេរើសជាពេទ្យ?

សំដាត់ ៖ អត់ទេ កាលនោះគេមិនរើសអារឿងអ្នកចេះមិនចេះទេ បើអ្នកចេះច្រើនតែងាប់ ។

ដារ៉ា ៖ ចុះពូថ្នាក់ទី៧យើងរៀនបានគួរសមដែរតើ ថ្នាក់ទី៧?

សំដាត់ ៖ ទេ! វាធម្មតា កុំតែយើងនិស្សិត ។

ដានី ៖ លោកពូចេះដំបូង ពេលដែលបែកឆ្នាំ៧៩មក ពូត្រូវបានគេឲ្យធ្វើកងចល័ត?

សំដាត់ ៖ បាទៗ ។

ដានី ៖ ចឹងកាលនឹងពេលដែលចូលកងចល័តនឹងយ៉ាងម៉េច គេជ្រើសរើសឲ្យយុវជន យុវនារីទាំងអស់ចូលកងចល័ត ឬក៏គេជ្រើសរើសយ៉ាងម៉េច?

សំផាត់ ៖ គេជ្រើសរើស ឲ្យតែដល់អាយុ១៦ឡើងទៅគេហៅទៅ ។

ដានី ៖ ចាប់ពីប៉ុន្មាន?

សំផាត់ ៖ ១៦, ១៨ យើងមើលតាមរូបផង អ្នកណារូបធំអាណាអាយុច្រើន អាណាអាយុតូចបាននៅទៅ ។

ដានី ៖ ពេលពូចូលធ្វើកងចល័តដំបូងគេឲ្យទៅខាងណា?

សំផាត់ ៖ ដំបូងគេឲ្យទៅគោករំចេក ។

ដានី ៖ ឲ្យទៅគោករំចេក?

សំផាត់ ៖ បាទ! គោករំចេកជិតភ្នំស្រុក ។

ដានី ៖ ធ្វើអីទៅ នៅគោករំចេក?

សំផាត់ ៖ ទៅលើកទំនប់ៗគេហៅទំនប់គោករំចេក ។

ដានី ៖ កាលពេលទៅលើកទំនប់នៅគោករំចេកនោះ ទៅគ្នាច្រើនទេ?

សំផាត់ ៖ អូ! ច្រើនណាស់ គ្រប់ស្រុកទៅ ។

ដានី ៖ គ្រប់ស្រុក?

សំផាត់ ៖ ក្នុងម៉ាតំបន់៥ ។

ដានី ៖ ចុះកាលនោះ អ្នកណាគេប្រធានគ្រប់គ្រងទៅ?

សំផាត់ ៖ អត់ស្គាល់ណាខ្ញុំ កាលនោះវាថ្មី ដំបូងអត់ដឹងអ្នកណាប្រធានៗ ។

ដានី ៖ ទៅលើកនៅគោករំចេកបានរយៈពេលប៉ុន្មាន?

សំផាត់ ៖ ខ្ញុំទៅដូចមិនយូរប្រហែលជាម៉ាអាទិត្យៗគេរួចៗ គេឲ្យត្រឡប់មកនៅជប់វិញ ។

ដានី ៖ នៅជប់វ៉ារី?

សំផាត់ ៖ បាទ! នៅជប់គេធ្វើសន្និបាទរួច គេបែកចែកកម្លាំង ខ្ញុំត្រូវមកនៅអារក្សបាក់-ក ផ្លូវចេញពីគោកលន់នេះ ។

ដារ៉ា ៖ ពេលធ្វើសន្និបាទនឹង សន្និបាទធំ ឬតូច?

សំផាត់ ៖ សន្និបាទម៉ាចល័តយើង កាលនោះមិនយល់អារឿងស្អីគេផង ព្រោះតែគេថាសន្និបាទទៅក៏ទៅអង្គុយនឹងគេ ។

ដារ៉ា ៖ មនុស្សច្រើន?

សំផាត់ ៖ អូ! រាប់ពាន់នាក់ ។

ដារ៉ា ៖ រាប់ពាន់ម៉ឺន?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ពេលហ្នឹងអ្នកណាឡើងនិយាយ ពូចាំ?

សំផាត់ ៖ អូ! អត់ចាំទេ ។

ដានី ៖ ចុះគណៈអធិបតីគេ ដូចថាគេធ្វើសន្និបាទ មានគណៈអធិបតីគេ?

សំផាត់ ៖ គ្រាន់តែស្គាល់ឈ្មោះ តាមោង មួយគាត់ចៅហ្វាយស្រុកបណ្ដោយ ។

ដានី ៖ តាមោង គាត់ចៅហ្វាយស្រុក?

សំផាត់ ៖ បាទ! គាត់ចៅហ្វាយស្រុក ក្រៅពីនោះអត់ស្គាល់ទេ ។

ដារ៉ា ៖ កាលហ្នឹងតាមោង គាត់ចៅហ្វាយស្រុកព្រះនេត្រព្រះ?

សំផាត់ ៖ តាមោង ចៅហ្វាយស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ លេខាស្រុក គេមិនហៅចៅហ្វាយទេ?

សំផាត់ ៖ ហ៊ើ! លេខាស្រុកហើយដឹង ដូចលេខាស្រុកនោះឯង ។

ដានី ៖ ពេលសន្និបាទហ្នឹង គ្នាច្រើនប្រជាជនទូទៅ ឬក៏មាន?

សំផាត់ ៖ ទេ! ចល័ត ។

ដានី ៖ តែកងចល័ត

សំផាត់ ៖ យុវជន យុវនារីប៉ុននោះឯង អត់មានចាស់ៗទេ ។

ដានី ៖ ចល័តនឹង ចល័តតែក្នុងស្រុកព្រះនេត្រព្រះ ឬក៏មានស្រុកផ្សេងដែរ មកចូលរួមដែរ ពេលធ្វើសន្និបាទហ្នុង?

សំផាត់ ៖ កាលនឹងដូចថាតែក្នុងស្រុកព្រះនេត្រព្រះ ។

ដានី ៖ ព្រះនេត្រព្រះ?

សំផាត់ ៖ បាទ!

ដានី ៖ ប្រហែលជាប៉ុន្មានទៅ?

សំផាត់ ៖ រាប់ពាន់នាក់ ពេញម៉ាវត្តជប់នោះឯង ។

ដារ៉ា ៖ អូ! គេធ្វើសន្និបាទនៅវត្តជប់?

សំផាត់ ៖ បាទ!

ដានី ៖ ដល់ពេលធ្វើសន្និបាទនឹងរយៈពេលប៉ុន្មាន?

សំផាត់ ៖ អត់យូរទេ ៣ថ្ងៃប៉ុននោះ ចប់ទៅគេបែងចែកកម្លាំងទៀត ។

ដានី ៖ គេនិយាយពីអីខ្លះ សន្និបាទ?

សំដាត់ ៖ អូ! ដឹងថានិយាយពីអីទេ យើងមិនដែលសួរដឹង ពុតែ គឺថា, ដើម្បី នោះច្រើន។

ដានី ៖ គឺថា ដើម្បី?

សំដាត់ ៖ នោះ អាពាក្យនោះច្រើនជាងគេហើយ។

ដារ៉ា ៖ ពុតែពាក្យ គឺថា ដើម្បី?

សំដាត់ ៖ ឲ្យយើងប្ដេជ្ញា លើកទំនប់ ជីកប្រឡាយ ធ្វើស្រែឲ្យបានផលច្រើន។

ដានី ៖ តាមោង គាត់ធ្វើគណអធិបតីខាងនឹងហើយ។ ហើយដល់ពេល៣ថ្ងៃហើយទៅ លោកពូត្រូវបានគេបញ្ជូនឲ្យទៅខាងអារក្សបាក់-ក?

សំដាត់ ៖ បាទ!

ដានី ៖ ទៅទាំងអស់គ្នា ឬក៏គេបែងចែកកម្លាំង?

សំដាត់ ៖ អត់ទេ គេបែងចែកកម្លាំង ខ្លះទៅណាទេ ខ្លះទៅចល័តតំបន់ អាខ្លះទៅស្ទឹណា វាបែងចែកច្រើនស្រេចតែគេរើស។ ឧបមាថាកងចល័តពិសេសគេ១០០នាក់ គេរើសបាន ១០០ គេទៅបាត់។ អាមកខាងណា ចល័តខាងណា អារក្សបាក់-កនេះ គេយកប៉ុន្មាន យើងមកខាងនេះមក។

ដានី ៖ ចុះកាលទៅចល័តនៅអារក្សបាក់-កហ្នឹង គេហៅចល័តអីគេ?

សំដាត់ ៖ អាហ្នឹងពួកចល័តស្រុក។

ដានី ៖ ចល័តស្រុក?

សំដាត់ ៖ បាទ!

ដានី ៖ ពីណាគេ អ្នកគ្រប់គ្រងអាហ្នឹងចល័តស្រុក?

សំដាត់ ៖ ភ្លេចហើយឈ្មោះប្រធានចល័ត អត់រកនឹកឈ្មោះឃើញទេ។

ដានី ៖ ភ្លេច?

សំដាត់ ៖ ភ្លេច។

ដានី ៖ ចុះខាងទៅផ្សេងៗទៀត ដូចជាលោកពូមានប្រសាសន៍មិញ ថាកងចល័តពិសេសអី?

សំដាត់ ៖ ម៉េចដឹង បើយើងនៅខុសគ្នា ពួកចល័តតំបន់អីយើងម៉េចស្គាល់គេ។

ដានី ៖ ចល័តតំបន់?

សំដាត់ ៖ ចល័តតំបន់ផ្សេង។

ដានី ៖ ចល័តតំបន់ផ្សេងទៀត?

សំដាត់ ៖ បាទ!

ដានី ៖ ចល័តតំបន់ គេទៅណាវិញទៅ?

សំផាត់ ៖ គេចល័តតំបន់ កាលនោះគេទៅលើកនៅអាងត្រពាំងថ្មផង មកទំនប់កំបោរ-ស្រះផង អានេះសុទ្ធតែកន្លែងចល័តតំបន់ហើយ ។

ដានី ៖ ពីណាគេធ្វើប្រធានចល័តតំបន់?

សំផាត់ ៖ អូ! អត់ស្គាល់ទេ ខ្ញុំអត់ដែលបានទៅផង ។

ដានី ៖ ចឹងកាលនឹងពូអត់បានទៅចូលខាងចល័តតំបន់ទៀតទេ?

សំផាត់ ៖ អត់ទេ ។

ដានី ៖ មកចល័តស្រុក ទៅលើកនៅអារក្សបាក់-កវិញ?

សំផាត់ ៖ បាទៗ ។

ដានី ៖ ឆ្នាំណាដែរ ពូកាលហ្នឹង?

សំផាត់ ៖ កាលហ្នឹងប្រហែលឆ្នាំ៧៦ ។

ដានី ៖ ខែប៉ុន្មាន?

សំផាត់ ៖ អត់ចាំទេ ។

ដានី ៖ ខែកាលហ្នឹងពេលជិត?

សំផាត់ ៖ បើយើងគិតពីរដូវ ប្រហែលជាអារដូវយើងស្ទូង ព្រោះមកស្ទូងស្រូវ លើកទំនប់បណ្ដើរ ស្ទូងបណ្ដើរ ធ្វើប្រព័ន្ធប្រឡាយហើយយើងស្ទូង ។

ដានី ៖ ជាទូទៅស្ទូងខែប៉ុន្មាន?

សំផាត់ ៖ ប្រហែលជាខែ៨ ខែ៩នេះ ។

ដានី ៖ ខែ៨ ខែ៩ៗ ប៉ុន្តែបើតាមពូស្មានមើលដូចថាពីឆ្នាំ៧៥ ពេលដែល ប៉ុល ពត ចូល១៧ មេសា ឆ្នាំ៧៥ ។ ចឹងពូទៅកន្លែងគោករំចេកហ្នឹងៗ ។ ទៅគោករំចេកបានរយៈពេលប៉ុន្មានបានត្រឡប់មកធ្វើ?

សំផាត់ ៖ អាហ្នឹងទៅៗអត់យូរទេ ប្រហែលជាម៉ោអាទិត្យ បើយើងនៅជប់ផង ចេញមកនៅអារក្សបាក់-ក យូរ ប៉ុនមិនដឹងរយៈពេលប៉ុន្មានទេ អត់ចាំទេ ។

ដានី ៖ លោកពូមានប្រសាសន៍មិញ ថាខែ៧ ខែ៨នឹង មានតែក្នុងឆ្នាំ៧៥?

សំផាត់ ៖ ទេ! ដូចជាដើម ពាក់កណ្ដាលឆ្នាំ ។

ដានី ៖ ចឹងពេលដែលមកកន្លែង អារក្សបាក់-កនឹង យើងធ្វើអីខ្លះទៀតទៅ?

សំផាត់ ៖ មានតែលើកប្រព័ន្ធភ្លឺ ស្ទូង ។

ដានី ៖ លើកប្រព័ន្ធភ្លឺ ស្អួន?

សំដាត់ ៖ បាទ!

ដានី ៖ គ្នាប៉ុន្មាននាក់?

សំដាត់ ៖ អូ! ច្រើន ដល់ពេលក្រោយមកដែលស្អួនរួចអីរួច គេដកអស់ មិនដឹងទៅខាងណាទៀត នៅតែខ្ញុំ៣០នាក់ នៅមើលសំណាប អឺ!នៅមើលស្រូវគេ យើងនៅមើលថែទឹកថែអី ។

ដារ៉ា ៖ កាលនឹងពូស្គាល់អ្នកណាខ្លះដែរ ជាអ្នកដែលធ្លាប់ធ្វើការជាមួយពូ មើលសំណាបមើលអី មានស្គាល់ឈ្មោះអ្នកណាខ្លះ?

សំដាត់ ៖ អូ! ភ្លេចអស់ហើយ ព្រោះអត់មានភូមិជាជុំគ្នា ច្រើនតែអ្នកឆ្ងាយពីគ្នា គេដកចំរុះគ្នាចូលគ្នាទៅ ។

ដានី ៖ ប្រហែលជាប៉ុន្មាននាក់?

សំដាត់ ៖ នៅប្រហែក៣០នាក់ នៅម៉ាកងតូច ។

ដានី ៖ ពីណាគេធ្វើប្រធានកាលនឹង?

សំដាត់ ៖ ទេ! ខ្ញុំភ្លេច រកនឹកអត់ឃើញ ។

ដានី ៖ នៅនឹងរយៈពេលប៉ុន្មានទៅ នៅអារក្សបាក់-កនឹង?

សំដាត់ ៖ ទេ! នៅរហូតដល់ស្រូវចេញ ។

ដានី ៖ រហូតដល់ស្រូវចេញៗខែប៉ុន្មាន?

សំដាត់ ៖ ចេញវាប្រហែលជាខែ១២ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ ដល់ពេលស្រូវចេញទៅ?

សំដាត់ ៖ កាលនឹងខ្ញុំមិនដឹងម៉េចបានត្រូវបានត្រឡប់ទៅភូមិវិញ ។

ដានី ៖ ត្រឡប់ទៅភូមិវិញ?

សំដាត់ ៖ ដូចជាគ្រុនក៏មិនដឹង គ្រុនមកដេកពេទ្យ ដល់ចេញពីពេទ្យទៅវិញគេឲ្យត្រឡប់ទៅភូមិ មើលចុះ ។

ដានី ៖ ចឹងពេលពូគ្រុន ពូមកដេកពេទ្យនៅណា?

សំដាត់ ៖ នៅស្វាយ ។

ដានី ៖ មកដេកពេទ្យនៅស្វាយ?

សំដាត់ ៖ សាលាលើ ។

ដានី ៖ នៅណាសាលាលើ?

សំដាត់ ៖ នេះអាសាលាលើ កាលនោះគេដាក់មន្ទីរពេទ្យ ។

ដានី ៖ គេហៅមន្ទីរពេទ្យ?

សំដាត់ ៖ បាទ!

ដានី ៖ ចុះលោកពូកាលនោះ ពូគ្រុនអីគេបានមកដេកពេទ្យនៅស្វាយ?

សំដាត់ ៖ គ្រុនកាលនោះដូចជាគ្រុនសន្ធប់ ដូចវាក្តៅខ្លាំង គេដឹកមកអត់ដឹងផង ។

ដានី ៖ មិនមែនគ្រុនចាញ់ទេ?

សំដាត់ ៖ ដូចជាមិនមែនគ្រុនចាញ់ តែគ្រុនចាញ់ អានឹងគេប្រើថ្នាំដែរ ។

ដានី ៖ ចឹងកាលនឹងពូមកដេកពេទ្យៗ នៅស្វាយនឹងគេហៅពេទ្យអីគេ?

សំដាត់ ៖ ពេទ្យតំបន់ ។

ដានី ៖ ពេទ្យតំបន់១៥ ។ ចុះពូមកដេកពេទ្យនឹងរយៈពេលប៉ុន្មានទៅ?

សំដាត់ ៖ ប្រហែលជា៨-១០ថ្ងៃ ។

ដានី ៖ ៨-១០ថ្ងៃ ហើយយ៉ាងម៉េចទៀត?

សំដាត់ ៖ ទៅវិញ សុំគេទៅវិញ វាជា ។

ដានី ៖ ពេលដែលជាហើយ យើងទៅវិញត្រូវទៅខ្លួនឯង?

សំដាត់ ៖ គេ សុំគេទៅ យើងរកឡានរកអីជិះខ្លួនយើង សុំគេដោយសារទៅៗចុះនៅកន្លែងចល័តនឹង ។

ដានី ៖ ចុះនៅកន្លែងចល័តៗនៅណា?

សំដាត់ ៖ នៅអារក្សបាក់-ក ។ ប៉ុនដល់ក្រោយមកមិនដឹងសុំគេយ៉ាងម៉េចបានៗទៅនៅផ្ទះវិញ វាក្អេចដែរ វាយូរដែរ ។

ដានី ៖ ទៅឆ្នាំណាដែលសុំគេទៅនៅផ្ទះនឹង?

សំដាត់ ៖ ទេ! អាររដូវស្រូវចេញនេះឯង ដើរចុងឆ្នាំ៧៥នេះ ។

ដានី ៖ ចុងឆ្នាំ៧៥ រដូវស្រូវចេញ ។ ចឹងពេលដែលពេលពូសុំទៅផ្ទះវិញ យ៉ាងម៉េចទៅធ្វើអីវិញនៅផ្ទះហ្នឹង?

សំដាត់ ៖ នៅផ្ទះ នៅធ្វើស្រែដែរ គេឲ្យគោម៉ានឹម ។

ដានី ៖ គេឲ្យគោម៉ានឹម?

សំដាត់ ៖ ដើរភ្ជួរ ។

ដានី ៖ ភ្ជួរនៅក្នុងកងអីទៅ?

សំផាត់ ៖ នៅក្នុងភូមិ ។

ដានី ៖ នៅក្នុងភូមិ ពេលដែលពូទៅអារក្សបាក់-ក ពូនៅក្នុងកងចល័ត?

សំផាត់ ៖ បាទ!

ដានី ៖ ដល់ពេលត្រឡប់ទៅក្នុងភូមិវិញ ទៅធ្វើការស្រែនៅក្នុងកងអីទៅ ក្នុងសហករណ៍ ឬក៏នៅក្នុងកង?

សំផាត់ ៖ នៅក្នុងសហករណ៍ តែយើងនៅតាមភូមិ ដូចថាម៉ាសហករណ៍វាមាន៣ភូមិចេះ យើងនៅភូមិកណ្តាល ៗដដែល ម៉ាភូមិកណ្តាលម៉ាក្រុម ។

ដានី ៖ មកនៅជាមួយឪពុកម្តាយវិញ?

សំផាត់ ៖ បាទៗ តែគេឲ្យទៅនៅការស្រែ ។

ដានី ៖ ឲ្យការស្រែ?

សំផាត់ ៖ ហ្នឹង ។

ដារ៉ា ៖ តែបើមើលពូ មិនជាមាឌធំប៉ុន្មានទេ នៅក្នុងសម័យនឹង?

សំផាត់ ៖ កាលនោះ ខ្ញុំអាយុប្រហែលជា១៩ឆ្នាំ ។

ដារ៉ា ៖ ១៩ឆ្នាំ បើនិយាយជាមាឌ រៀងរៅដូចជាមិនធំប៉ុន្មាន?

សំផាត់ ៖ ទេ! កាលនោះមិនធំដល់ប៉ុននេះទេ ។

ដារ៉ា ៖ តែម៉េចគេឲ្យទៅការស្រែកើត បើនង្គ័ល គោអីធំដែរ ពូម៉េចទៅ?

សំផាត់ ៖ ទេ! មានអី យើងអ្នកស្រែ យើងធ្លាប់ធ្វើស្រែតាំងពីដើម គេធ្លាប់ដឹងទាំងអស់តែគ្នា ។

ដារ៉ា ៖ ហើយកាលហ្នឹង ប្រធានភូមិពូអ្នកណាគេ?

សំផាត់ ៖ ប្រធានភូមិឈ្មោះ កាលនោះ ឈ្មោះ តាឈីវ ។

ដានី ៖ តាឈីវ?

សំផាត់ ៖ បាទ! ឈីវ ឥឡូវទៅនៅបារាំង ។

ដារ៉ា ៖ តាឈីវហ្នឹង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ នៅបារាំង?

សំផាត់ ៖ បាទ!

ដានី ៖ គាត់ប្រធានភូមិអី?

សំផាត់ ៖ ភូមិកណ្តាល ។

ដារ៉ា ៖ ហើយដល់ពេលឃុំ?

សំដាត់ ៖ តាក្រុក ។

ដារ៉ា ៖ ចុះតាក្រុកហ្នឹង គាត់ធ្វើឃុំតាំងពី?

សំដាត់ ៖ ៧៥មក ។

ដារ៉ា ៖ ពេលបែក៧៥ភ្លាម ចូលមកគឺតាក្រុកម៉ង?

សំដាត់ ៖ ចូលមក គឺគាត់មេឃុំ ។

ដារ៉ា ៖ ពូថាល្បីថាកាច ថាអី?

សំដាត់ ៖ ទេ! តាក្រុក បើគិតថាកាចក៏ដូចជាមិនមែនជាកាច ព្រោះកាលសម័យគាត់នៅក៏មិនមែនជាស្លាប់ដូចសម័យនិរតីដែរ ដូចថាគាត់ចេះយល់យោគខ្លះ ។

ដានី ៖ តាក្រុកហ្នឹង គាត់អ្នកស្រុកភូមិនៅណាដែរទៅ?

សំដាត់ ៖ អ្នកនៅខេត្តសៀមរាប ។

ដានី ៖ អ្នកខេត្តសៀមរាប?

សំដាត់ ៖ បាទ! គេហៅនៅភូមិស្ពឺទេ ភូមិខ្ទុង ប៉ុនគាត់ស្លាប់ហើយ ។

ដានី ៖ ស្រុកអីគេអានឹង?

សំដាត់ ៖ តាមមើលស្រុកក្រឡាញ់ ។

ដារ៉ា ៖ នៅជាប់ព្រះនេត្រព្រះដែរ?

សំដាត់ ៖ បាទ! ព្រំប្រទល់ជាប់គ្នាខេត្ត ។

ដានី ៖ ចុះលោកពូ ម៉េចបានគេ សម័យគេដូចថាអ្នកដឹកនាំហ្នឹង មកពីខាងក្រឡាញ់ ខាងសៀមរាប មកដឹកនាំនៅព្រះនេត្រព្រះហ្នឹង?

សំដាត់ ៖ អូ! មិនដែលដឹងទេ អត់ដឹងធ្វើម៉េចទេ កាលនោះពួកនិរតីមកដូរ ។

ដានី ៖ ចុះតាមោង?

សំដាត់ ៖ តាមោង ពួកនិរតីមក ឆាប់បាត់ហើយ ។

ដានី ៖ ប៉ុន្តែតាមោង គាត់អ្នកស្រុកណាដែរ?

សំដាត់ ៖ អត់ស្គាល់ ដូចមិនមែនអ្នកនឹងខេត្តយើងនេះទេ គាត់និយាយចឹងៗ ។

ដានី ៖ ចុះលោកពូ ចឹងពេលដែលលោកពូមកក្នុងភូមិ មកភ្ជួរស្រែនឹងយ៉ាងម៉េចទៀតទៅ ពូអាចរៀបរាប់ មកភ្ជួរស្រែបានរយៈពេលប៉ុន្មានបានផ្លាស់ប្តូរទៀត?

សំដាត់ ៖ មិនដឹងថាក្នុងឆ្នាំណា ដែលគេដកខ្ញុំធ្វើពេទ្យ ខ្ញុំវាភ្លេច ប្រហែលជាឆ្នាំ៧៦ ។

ដានី ៖ ៧៦?

សំផាត់ ៖ បាទ!

ដានី ៖ ដូចថាពូមកពី មិញពូមានប្រសាសន៍?

សំផាត់ ៖ ចេញពីចល័តទៅនៅភ្នូរស្រែនៅក្នុងភូមិ ។

ដានី ៖ មកភ្នូរស្រែនឹង នៅក្នុងពេលដែលស្រូវចេញៗ ពូមានប្រសាសន៍មិញថាខែ១២ ប្រហែលជាចុងឆ្នាំ៧៥ ។ ចឹងមកភ្នូរស្រែនឹងបានរយៈពេលប៉ុន្មាន ដែលគេដកលោកពូទៅធ្វើពេទ្យ ធ្វើអី?

សំផាត់ ៖ ធ្វើស្រែម៉ារដូវៗ យើងមិនដឹងថាក្នុងខែណា យើងឡើងពីធ្វើស្រែមកវិញ បានធ្វើស្រែហើយរួច មានតែខែ៨ខែអីនឹង មកនៅឡើងមកភូមិវិញ អឺ!គេរើសពេទ្យបណ្ដោយ ។

ដានី ៖ កាលនឹងគេរើសពេទ្យនឹង រើសគ្នាប៉ុន្មាននាក់ទៅ?

សំផាត់ ៖ រើសតែ៣ ។

ដានី ៖ រើសតែ៣ ដែលពូមានប្រសាសន៍មិញ?

សំផាត់ ៖ បាទៗ ។

ដានី ៖ ដែលពួកគាត់មិញថានៅខាងប្រាសាទ នៅអីមិញនឹង សុទ្ធតែអ្នកនៅក្នុងភូមិ?

សំផាត់ ៖ នៅក្នុងភូមិយើង ។

ដានី ៖ ភូមិកណ្ដាលទាំងអស់គ្នា?

សំផាត់ ៖ បាទៗ ។

ដានី ៖ គេរើស៣នាក់នឹង គេផ្អែកទៅលើយ៉ាងម៉េច បានគេរើសយកតែ៣នាក់មកធ្វើពេទ្យ?

សំផាត់ ៖ អានឹងស្រេចតែលើមេភូមិគេទេ ដូចថាសំឡឹងឃើញណា គេហៅទៅ ។

ដានី ៖ គេអាចថា អ្នកដែលគេជ្រើសរើសទៅយើងមានវណ្ណៈភាពយ៉ាងម៉េច យើងស្អាតស្អំអីយ៉ាងម៉េចដែរ បានគេជ្រើសរើសយកទៅធ្វើពេទ្យ?

សំផាត់ ៖ កាលនោះគេចេះតែរើស មិនយកអ្នកជាប់និន្នាការដូចថាតែយើង កាលសម័យលន់ នល់យើងធ្វើកុម្ម៉ង់ដូរ ឬធ្វើទាហានគេអត់យកទេ ។

ដានី ៖ ចុះអ្នកថ្មី អ្នក១៧មេសា គេជ្រើសរើសយកធ្វើពេទ្យដែរអត់?

សំផាត់ ៖ កាលនោះ ដូចអត់ទាន់មក ដូចមិនទាន់មក ។

ដានី ៖ បាទ?

សំផាត់ ៖ កាលនោះគេជម្លៀសមកហើយ គេអត់សួរយកទេ ។

ដានី ៖ ចឹងដល់ពេលត្រូវបានជ្រើសរើសទៅធ្វើពេទ្យហើយ ទៅរៀនសូត្រខាងវិជ្ជាពេទ្យហ្នឹង នៅណាទៅ?

សំផាត់ ៖ កាលនោះ គេឲ្យមករៀននៅស្វាយនេះ រៀន៣ខែ ។

ដានី ៖ រៀននៅស្វាយនេះ៣ខែ?

សំផាត់ ៖ បាទ!

ដានី ៖ រៀននៅកន្លែងណាទៅ?

សំផាត់ ៖ នេះៗ រៀនអាផ្លូវចុះទៅមាត់ស្ទឹងខាងនោះ ។

ដានី ៖ អានឹងកន្លែងនឹងកន្លែងអីគេ កន្លែងដែលគេឲ្យពូ?

សំផាត់ ៖ កន្លែងពេទ្យគ្រូនចាញ់ ។

ដានី ៖ ពេទ្យគ្រុនចាញ់?

សំផាត់ ៖ បាទ!

ដានី ៖ ពេទ្យរបស់ថ្នាក់អីគេ?

សំផាត់ ៖ ថ្នាក់តំបន់ ។

ដានី ៖ ពេទ្យរបស់តំបន់ រៀន៣ខែនៅហ្នឹង?

សំផាត់ ៖ រៀន៣ខែ ។

ដានី ៖ ពីណាគេ ធ្វើប្រធានពេទ្យនៅកន្លែងពេទ្យគ្រុនចាញ់?

សំផាត់ ៖ ភ្លេចហើយ ។

ដានី ៖ បាទ?

សំផាត់ ៖ ភ្លេចហើយ ។

ដានី ៖ ភ្លេចហើយ?

សំផាត់ ៖ រកនឹកមិនឃើញ វាយូរពេក រយៈពេលខ្ញីយើងចាំអត់បាន ។

ដានី ៖ ពូចាំ ថាពេលពូចេញទៅវិញ នៅបាន៣ខែចេញទៅវិញ នៅចាំខែឆ្នាំទេ?

សំផាត់ ៖ អត់ចាំទេ ។

ដានី ៖ តែក្នុងឆ្នាំ៧០ប៉ុន្មាន?

សំផាត់ ៖ ប្រហែលជាចុងឆ្នាំ៧៦ក៏មិនដឹង វាភ្លេចទៅ វាយូរពេក បើកាលនោះវាមិនដែលបានគិតគូពីថ្ងៃខែអីផង បើវាស៊ីមិនសូវឆ្អែតផង ។

ដានី ៖ យ៉ាងម៉េច ពេលដែលពូចេញទៅវិញ គេចាត់ឲ្យពូធ្វើការយ៉ាងម៉េចទៀតទៅ?

សំផាត់ ៖ អូ! ចេញទៅវិញ គេឲ្យទៅនៅកន្លែងស្រុក ។

ដានី ៖ នៅកន្លែងស្រុក?

សំផាត់ ៖ បាទ! ដល់នៅកន្លែងស្រុកបានគេបែងចែកទៀត ខ្ញុំត្រូវទៅនៅភ្នំលៀប ។

ដានី ៖ នៅ២នាក់ទៀត គេឲ្យទៅនៅណា?

សំផាត់ ៖ អត់ទេ ដែលមករៀនក្នុងដែលរើសជុំគ្នា៣នាក់ មកតែខ្ញុំម្នាក់ទេ ដែលគេរើសមករៀនៗស្វាយ(ស្វាយស៊ីសាផុន) ។

ដានី ៖ មកតែពូម្នាក់ទេ?

សំផាត់ ៖ បាទ! ម៉ាឃុំគេយកតែម្នាក់ទេ ។

ដានី ៖ ចឹងពូបានមករៀនស្វាយតែម្នាក់ឯងទេ ក្នុងចំណោម៣នាក់ហ្នឹង?

សំផាត់ ៖ បាទ!

ដានី ៖ ហើយយើងមករៀនហ្នឹង រៀនតែពីគ្រូនចាញ់ទេ?

សំផាត់ ៖ បាទ! រៀនតែគ្រូនចាញ់ម៉ាមុខ ។

ដានី ៖ ដល់ពេលបន្ទាប់ពីចប់ពីហ្នឹងមក ពូទៅកន្លែងមន្ទីរស្រុកវិញ កាលជំនាន់នឹងគណៈស្រុកគាមោងដដែល ឬក៏មានផ្លាស់ប្តូរហើយ?

សំផាត់ ៖ នៅទេ នៅ ។

ដារ៉ា ៖ មន្ទីរស្រុកគេនៅកន្លែងណា?

សំផាត់ ៖ នៅកន្លែងស្រុកចាស់ អឺ!ស្រុកថ្មីយើងសព្វថ្ងៃ ។

ដារ៉ា ៖ នៅកន្លែងសាលាស្រុកព្រះនេត្រព្រះ?

សំផាត់ ៖ បាទៗ ។

ដារ៉ា ៖ កន្លែងនឹងជាមន្ទីរស្រុកពីជំនាន់ខ្មែរក្រហម?

សំផាត់ ៖ មន្ទីរស្រុក ។

ដារ៉ា ៖ ហើយមកដល់ទៅ គេបែកចែកពីឲ្យទៅនៅ?

សំផាត់ ៖ នៅភ្នំលៀប ។

ដារ៉ា ៖ នៅកន្លែងមន្ទីរស្រុកភ្នំលៀប?

សំផាត់ ៖ នៅកន្លែងឃុំ ។

ដារ៉ា ៖ តែមានមន្ទីរពេទ្យនៅហ្នុងមួយ?

សំផាត់ ៖ ទេ! អត់មានទេ អូ! មានមន្ទីរពេទ្យកន្លែងស្រុកនោះណា អានោះឃុំ គេបែងចែកទៅតាមឃុំ អានោះវាចំណុះឲ្យស្រុកព្រះនេត្រព្រះ ។

ដានី ៖ ចុះពូមានដឹងថា មូលហេតុអីបានគេបែងចែកពូទៅខាងភ្នំលៀប?

សំផាត់ ៖ កាលនោះ ពេទ្យគ្រូនចាញ់ គេទើបជ្រើសរើស ហើយមករៀនគ្រប់ភូមិមក ស្រេចតែស្រុកគេបែងចែក អាខ្លះអី ខ្ញុំមកពីភូមិព្រះនេត្រព្រះ គេអត់ឲ្យមកវិញដែរ គេឲ្យទៅភូមិផ្សេង អាអ្នកមកពីនោះគេឲ្យមកនៅនេះ ។

ដានី ៖ ចុះពេលដែលពូទៅដល់ភ្នំលៀបយ៉ាងម៉េចទៅ យើងធ្វើការយ៉ាងម៉េច យើងធ្វើការជាមួយពីណា ទាក់ទងអីយ៉ាងម៉េច?

សំផាត់ ៖ យើងទៅនៅមន្ទីរពេទ្យឃុំទៅ ។

ដានី ៖ ចុះលោកពូពេលដែលពូទៅដល់ភ្នំលៀបនឹងយ៉ាងម៉េចទៅ យើងទៅធ្វើការយ៉ាងម៉េចខ្លះ?

សំផាត់ ៖ យើងនៅធ្វើពេទ្យនោះ យើងដើរតាមភូមិ តាមអី បើយើងនៅពេទ្យឃុំវាមានភូមិទៀតរៀបចំតាមភូមិឲ្យមានពេទ្យគ្រូនចាញ់ទៅ ។

ដារ៉ា ៖ នៅឃុំភ្នំលៀបនឹង ឃុំភ្នំលៀបចឹង?

សំផាត់ ៖ បាទៗ ។

ដារ៉ា ៖ នៅឃុំភ្នំលៀបនឹង មានប៉ុន្មានភូមិ កាលនឹង?

សំផាត់ ៖ កាលនោះវាមាន គេចែកទៅតាមសហករណ៍ទេ ។

ដារ៉ា ៖ ហើយពេលនឹង ដែលពូទៅធ្វើពេទ្យខាងគ្រូនចាញ់នៅភ្នំលៀបនឹង អ្នកណាមេឃុំអីទៅ?

សំផាត់ ៖ កាលនោះឈ្មោះ តាផាង ។

ដារ៉ា ៖ ឈ្មោះ ផាង?

សំផាត់ ៖ ឈ្មោះ ផាង គាត់មេឃុំ តែដល់ក្រោយមក និរតីចូលមកគេចាប់គាត់យកទៅវ៉ៃចោលបាត់ទៅ ។ ដល់ពេលយាយចែមចូលមក ពួកនិរតី យាយចែម ។

ដានី ៖ ប៉ុន្តែពូទៅនៅកន្លែងភ្នំលៀបនឹងបានរយៈ បានយាយចែមគាត់ចូលមក?

សំផាត់ ៖ យូរគ្រាន់ដែរ គិតមើលខ្ញុំទៅជាប់គុកបាន៨ខែ វៀតណាមចូល ខ្ញុំចេញពីនេះទៅៗនៅភ្នំលៀបរហូត ។

ដានី ៖ ដល់ពេលពូជាប់គុកបាន៨ខែ បានវៀតណាមចូល?

សំផាត់ ៖ បាទ!

ដានី ៖ ចុះពូកាលនឹងពូទៅធ្វើប្រធានពេទ្យនៅភ្នំលៀបនឹង?

សំផាត់ : ប្រធានពេទ្យគ្រូនចាញ់ទេ អាប្រធានពេទ្យទូទៅគេផ្សេងពីលើយើងទៀត ។

ដានី : ពីណាគេ ប្រធានពេទ្យទូទៅ?

សំផាត់ : ពួកនិរតីនេះឯង ។

ដារ៉ា : និរតីមានតាំងពីពេលហ្នឹងម៉ង?

សំផាត់ : បាទ! ចាប់ពីពេលដែលខ្ញុំទៅនៅនោះ និរតីគេចាប់មកហើយ ។

ដារ៉ា : ពូទៅបានប៉ុន ពូទៅដល់ភូមមាននិរតីនៅហ្នឹង ឬក៏យ៉ាងម៉េច?

សំផាត់ : មានគេចាប់ផ្ដើមមកហើយ គេមកគ្រប់គ្រង ។

ដានី : ចុះយាយថែមមកនៅ ដែលពូទៅ?

សំផាត់ : មកហើយ យាយថែមនឹងគាត់ចៅហ្វាយស្រុកក្រោយមក ។ យាយថែម គាត់នៅភ្នំលៀប គាត់មិននៅសាលាស្រុកជប់ទេ ។

ដានី : អត់ទៅសាលាស្រុកជប់ទេ ប៉ុន្តែគាត់ទៅនៅភ្នំលៀប?

សំផាត់ : គាត់ទៅនៅភ្នំលៀប គាត់គ្រប់គ្រងម៉ាស្រុក ។

ដារ៉ា : ចឹងកន្លែងដែលគាត់ស្នាក់នៅប្រចាំនៅភ្នំលៀប?

សំផាត់ : បាទ!

ដារ៉ា : ហើយពូមានប្រសាសន៍មុន ពេលដែលពូត្រឡប់ទៅភ្នំលៀបវិញនឹង ថាតាមោងនៅទេ?

សំផាត់ : ទេ! អានោះមុនៗ កាលនោះមិនទាន់និរតីមកទេ ខ្ញុំនៅៗជប់ ដល់ពេលគេរៀបចំចាប់អីរួចទៅ បានគេបែងចែកពួកខ្ញុំទៅនៅភ្នំលៀប អានោះពួកនិរតីមកហើយ ។

ដារ៉ា : ចឹងពេលដែលពូទៅដល់ភ្នំលៀបទៅធ្វើពេទ្យគ្រូនចាញ់ទទួលផ្នែកខាងគ្រូនចាញ់នឹង ចឹងខាងពួកនិរតីមកហើយ?

សំផាត់ : មកហើយ ។

ដារ៉ា : ហើយពេលហ្នឹង គឺឃុំឈ្មោះ តាធាង?

សំផាត់ : ឈ្មោះតាធាងនោះ និរតីមកគេចាប់ហើយ កាលនោះខ្ញុំទៅដល់មកបានប៉ុន្មានថ្ងៃគេចាប់បាត់ ។

ដារ៉ា : គេចាប់តាធាងហ្នឹង?

សំផាត់ : បាទ!

ដារ៉ា : អ្នកណាឡើងជំនួសតាធាងទៅ?

សំផាត់ : ឈ្មោះស្អីទេ! ឈ្មោះ តាកាន់ ។

ដានី ៖ ឈ្មោះ តាកាន់?

សំដាត់ ៖ បាទ! អានោះគេឡើងមេឃុំម្តង ។

ដារ៉ា ៖ តាកាន់ឡើងមេឃុំពេលនឹង?

សំដាត់ ៖ បាទ!

ដារ៉ា ៖ ហើយពេលនឹងដឹងព្វថាយាយថែមនឹងឡើងជាគណៈស្រុក?

សំដាត់ ៖ យាយថែមគាត់ចៅហ្វាយស្រុក គណៈស្រុក ។

ដារ៉ា ៖ ពេលពូធ្វើការនៅភ្នំលៀបនឹង ជាពេទ្យ ពូបានឃើញតាកាន់ច្បាស់?

សំដាត់ ៖ អូ!ស្គាល់ៗច្បាស់ គាត់ចេញចូល ។

ដារ៉ា ៖ ចេញចូល ហើយតាកាន់នឹង មានរូបរាងម៉េចដែរ តាមពូសង្កេតមើល?

សំដាត់ ៖ មាឌ មិនជាធំទេ រៀងខ្មៅបន្តិច ។

ដារ៉ា ៖ តែចំណាស់ណាដែរ?

សំដាត់ ៖ កាន់ កាលនោះ អាយុគាត់ប្រហែលខ្ទង់៣០លើស ។

ដារ៉ា ៖ ចឹងទេ! មិនទាន់...?

សំដាត់ ៖ បាទ! ជិត៤០ ជិតអីប៉ុណ្ណឹង ។

ដារ៉ា ៖ តាកាន់គាត់មកនៅជាម៉េច?

សំដាត់ ៖ អានឹងមកក្នុងចង្កោមគ្រួសារទាំងគាត់ នៅក្នុងចង្កោមយាយថែមទាំងអស់ គេមកទាំងគ្រួសារៗគេមកនៅគ្រប់គ្រង ។

ដារ៉ា ៖ ហើយពូនៅភ្នំលៀបនឹង បានធ្លាប់ឃើញយាយថែម?

សំដាត់ ៖ មកស្គាល់ ធ្លាប់ចេញចូលផ្ទះគាត់ ។

ដារ៉ា ៖ ផ្ទះគាត់នៅម្តុំណា?

សំដាត់ ៖ នៅសាលាឃុំចាស់គេ សាលាឃុំសព្វថ្ងៃ ។

ដារ៉ា ៖ សាលាឃុំភ្នំលៀបរាល់ថ្ងៃ?

សំដាត់ ៖ បាទ! នៅម្តុំ ។

ដារ៉ា ៖ ព្វថាផ្ទះគាត់នៅជិតកន្លែងសាលាពេទ្យ?

សំដាត់ ៖ ផ្ទះគាត់ទៀម ផ្ទះគាត់នៅផ្ទះទៀមនឹងដី ។

ដារ៉ា ៖ ទៀមដី?

សំដាត់ ៖ បាទ! ដូចថាសាលាឃុំចាស់នៅខាងកើតចេះ ផ្ទះគាត់នៅខាងលិច ។

ដារ៉ា ៖ ខាងលិច?

សំផាត់ ៖ ខាងលិច អាសាលាឃុំចាស់គេ ។

ដារ៉ា ៖ គាត់នៅនឹងជាប្រចាំ?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ចឹងពូរស់នៅនឹងបានមានទំនាក់ទំនងអីជាមួយយាយថែមដែរ?

សំផាត់ ៖ ធ្លាប់ចេញចូល បើយើងនៅពេទ្យនោះ ។

ដារ៉ា ៖ ធ្លាប់ចេញចូលនឹង ចេញចូលជាលក្ខណៈទៅព្យាបាល ឬយ៉ាងម៉េច?

សំផាត់ ៖ លក្ខណៈព្យាបាលផង ឬក៏យើងដូចថាទំនាក់ទំនងការងារ ដូចថាពេទ្យឃុំវាត្រូវមានចុះតាមសហករណ៍ ។ កាលនោះចុះតាមសហករណ៍វាតឹង យើងអត់មានលិខិតស្នាម គេចាប់ ។ ហើយបើមិនទំនាក់ទំនងគាត់ មានសំបុត្រស្នាមទេ ទៅអត់បាន ។ ហើយគាត់ចេញសំបុត្រឲ្យមក សម្រាប់ដើរ ។

ដារ៉ា ៖ ចុះការចេញសំបុត្រស្នាមនឹង ចេញពីយាយថែម ឬចេញពីតាកាន់?

សំផាត់ ៖ ចេញពីយាយថែមតែម្ដង ។

ដារ៉ា ៖ ចុះយាយថែមធ្វើការងារអត់ឆ្លងឃុំទេចុះ?

សំផាត់ ៖ ព្រោះកាលនោះសំបុត្រឃុំវាដើរអត់សូវស្រួល គេអត់សូវទុកចិត្ត ហើយគាត់ចេញសំបុត្រឲ្យ បានដើរទៅ ។

ដារ៉ា ៖ ចឹងទាល់តែគណៈស្រុក? យាយថែមអ្នកចេញម៉ង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ កាលនឹងចេញសំបុត្រមាន...?

សំផាត់ ៖ មានត្រាដែរ ។

ដារ៉ា ៖ ចឹងមានន័យថាយាយថែម គាត់កាន់ត្រាដែរ?

សំផាត់ ៖ គាត់គណៈស្រុក ។

ដារ៉ា ៖ ត្រារបៀបម៉េចទៅពូ?

សំផាត់ ៖ ត្រាយើងដូចយើងសព្វថ្ងៃ អាត្រាមូលក្រហមដាក់កម្ពុជាប្រជាធិបតេយ្យ ។

ដារ៉ា ៖ ចឹងយាយថែម មានត្រានឹង?

សំផាត់ ៖ មាន ។

ដារ៉ា ៖ វិពណ៌អី?

សំផាត់ ៖ ក្រហម ។

ដារ៉ា ៖ ពណ៌ក្រហមម៉ង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ហើយអក្សរយាយថែម ឬក៏អក្សរអ្នកណា?

សំផាត់ ៖ អូ! សំបុត្រវ៉ែអង្គុលីលេខ១រូប បានគាត់គ្រាន់តែសរសេរដាក់ឈ្មោះគាត់ គាត់វ៉ៃត្រាបណ្ដោយ ។

ដារ៉ា ៖ ដាក់ថាម៉េច ឈ្មោះគាត់?

សំផាត់ ៖ ជីងស្ទីថែម ខ្ញុំភ្លេចត្រកូលគាត់ ។ ហ៉េ! យាយថែមគាត់នៅតើ ឆ្នាំមុនមកសិក្ខាសាលានៅត្រពាំងកាន់នេះឯង ឯកឧត្តមស្ទីខាងអប់រំនាំគាត់ដើរ ការពិតអាយុគាត់ច្រើនដែរ ។

ដារ៉ា ៖ បើពូឃើញគាត់ឥឡូវ ពូចាំទេ?

សំផាត់ ៖ វាដូចជាវៀងប្រហាក់ប្រហែលវាយូរហើយ៣០ឆ្នាំទៅហើយ ។

ដារ៉ា ៖ ចុះកាលពូនៅកន្លែងភ្នំលៀបនឹង ពេលពូបានជួបយាយថែម យាយអី ពូមានការភ័យ ឬក៏បារម្ភអីដែរ ឬក៏ខ្លាចគាត់អីដែរ?

សំផាត់ ៖ ទេ! កាលនោះវាមិនមានខុស យើងមានខ្លាចអីគាត់ ។

ដារ៉ា ៖ គាត់មើលទៅ ដូចថាយើងមើលពីខាងក្រៅ គាត់ជាមនុស្សយ៉ាងម៉េចដែរ បើតាមពូសង្កេតមើល?

សំផាត់ ៖ គាត់មិនមែនជាឃោរឃៅ អាគេអ្នកបញ្ជាចុះ វាពិបាកសន្និដ្ឋាន គេមេចតែភ្នែកទៅយើងឆាប់ក៏មាន អាការខុស ។

ដារ៉ា ៖ តែពេលដែលពូចូលទៅជួបគាត់ ចូលអីចឹង ពូអត់មានអារម្មណ៍ភ័យខ្លាចអីទេ?

សំផាត់ ៖ ទេ! កាលនោះមិនមានទេ ធម្មតា គ្រាន់តែដល់ក្រោយមក គាត់អ្នកបញ្ជាឲ្យគេយកខ្ញុំទៅដាក់គុក ។

ដារ៉ា ៖ ចឹងវិញ?

សំផាត់ ៖ បាទ!

ដារ៉ា ៖ រស់នៅនឹងបានប៉ុន្មានខែ ប៉ុន្មានឆ្នាំ បានពូត្រូវបានគេចាប់ដាក់គុក?

សំផាត់ ៖ ខ្ញុំអត់ចាំទេ គ្រាន់ខ្ញុំចាំថា ខ្ញុំជាប់គុកបាន៤ខែ ក៏វៀតណាមចូល ។

ដារ៉ា ៖ តែពេលចង់និយាយថា ពេលដែលពូទៅរស់នៅកន្លែងភ្នំលៀបនឹង បានស្គាល់គាកាន់ បានស្គាល់យាយថែមនឹង រយៈពេលយូរ រយៈពេលវែង?

សំផាត់ ៖ រយៈពេលវាវែងគ្រាន់ដែររហូតថា យើងប្រាប់ថារហូតដល់ពេលខ្ញុំជាប់គុក ។

ដានី ៖ បានរហូតដល់ឆ្នាំ ម៉ាឆ្នាំៗ ឬម៉ាឆ្នាំជាង ឬប៉ុន្មាន?

សំផាត់ ៖ គិតដល់ឆ្នាំ៧៩ គិតទៅយើងឆ្នាំ៧៩ ប្រហែលជាខែ៨ ប្រហែលជាខែ៨ជាប់គុកហើយ ។

ដានី ៖ ព្រោះវៀតណាមចូលឆ្នាំ៧៩ ខែ១ឆ្នាំ៧៩ វៀតណាមចូលភ្នំពេញហើយ?

សំផាត់ ៖ ខ្ញុំប្រហែលជាជាប់គុកឆ្នាំ ប្រហែលជាខែ៨ ។

ដានី ៖ ខែ៨ ឆ្នាំណា?

សំផាត់ ៖ អឺ! ឆ្នាំ៧៩ អឺ!ឆ្នាំ៨៩ ។

ដានី ៖ ៧៨?

សំផាត់ ៖ អឺ! ប្រហែល៧៨ ។

ដារ៉ា ៖ ព្រោះវៀតណាមចូល ខែ១ឆ្នាំ៧៩?

សំផាត់ ៖ បាទៗ ត្រូវហើយ ។

ដារ៉ា ៖ ចឹងបើពូជាប់គុក វាអាចថាជាប់គុកក្នុង៧៨ ខែ៨?

សំផាត់ ៖ ដើម៧៨ ខែ៨ ។

ដារ៉ា ៖ ច្បាស់ហើយពូ?

សំផាត់ ៖ បាទ! ប្រហែលប៉ុននោះឯង រយៈពេល ។

ដារ៉ា ៖ ដូចជាមានមូលហេតុអី បាន?

សំផាត់ ៖ មូលហេតុ កាលនោះ ខ្ញុំនៅជុំគ្នានោះ ដូចថាការរស់នៅវាដូចស៊ីចុកវាអត់សូវស្រុះស្រួលគ្នា ឯកភាពគ្នា គេស៊ីឆ្ងាញ់ដូចយើងស៊ីអត់ឆ្ងាញ់ទៅ ក្រោយពេលក្នុងម៉ាអាទិត្យអី គេអង្គុយប្រជុំម្តងគេលើកស្វ័យតិទៀន ឃើញគេខុសអីគេឲ្យតិទៀនគេ ដល់ក្រោយមកខ្ញុំតិទៀនពីរឿងស៊ីចុកនោះឯង ។

ដារ៉ា ៖ តិទៀនថាម៉េចទៅពូ?

សំផាត់ ៖ តិទៀនពីរឿងស៊ីអត់ឯកភាពគ្នា ។ ដូចថាគេប្រធានគេស៊ីស្ងោរមាន់ យើងស៊ីបាយអីទៅហើយយើងកូនចៅយើងស៊ីបបរ ឬក៏ម្ហូប ត្រីសាច់ អំបិល ម្ទេសអីទៅ គេទឹងកន្លែងនោះឯងបានគេទៅរាយការណ៍ឲ្យយាយថែម យកខ្ញុំទៅដាក់គុក ។

ដារ៉ា ៖ ចឹងការដែលប្រជុំរិះគន់នឹង នៅក្នុងក្រុមរបស់ពូ?

សំផាត់ ៖ នៅក្នុងពេទ្យឃុំ ។

ដារ៉ា ៖ នៅពេទ្យឃុំ?

សំផាត់ : បាទ!

ដារ៉ា : ចឹងបានន័យថាមានគាកាន់ ចូលរួមដែល ពេលប្រជុំ?

សំផាត់ : អត់ទេ ប្រជុំតែក្រុមពេទ្យតែម្ដង ។

ដារ៉ា : តែក្រុមពេទ្យទេ?

សំផាត់ : បាទ!

ដារ៉ា : កាលហ្នឹងអ្នកណាប្រធានពេទ្យ?

សំផាត់ : ប្រធានពេទ្យស្រី ឈ្មោះ ភ្លេចឈ្មោះវាទៀត ចាំបានឈ្មោះមីមួយឈ្មោះ មីលី ។

ដារ៉ា : ឈ្មោះ លី?

សំផាត់ : បាទ! គ្នាគេ២នាក់ ។ ឥឡូវមិនដឹងជាគេនៅខាងណា ។

ដារ៉ា : ចឹងក្នុងចំណោម២នាក់ហ្នឹង ឈ្មោះ លី ជាអ្នករាយការណ៍ ឬក៏ម៉េច?

សំផាត់ : ឈ្មោះ លី នោះឯង គេប្រធានពេទ្យ ។

ដារ៉ា : ចឹងពេលប្រជុំរាល់ដងជាមួយក្រុមពេទ្យហ្នឹង មានគាកាន់ជាឃុំមកចូលរួម យាយថែម?

សំផាត់ : អត់ទេ យើងប្រជុំពេទ្យគេមិនដែលមកទេ យើងប្រជុំជីវភាព ដូចថាប្រជុំប្រចាំថ្ងៃគេហ្នឹង គេអត់មកទេ ។

ដារ៉ា : ចឹងពួរិះគន់រឿងហូបចុក?

សំផាត់ : រិះគន់រឿងស៊ីចុកតិចតួច កើតទៅរឿងជាប់គុក ។

ដារ៉ា : ចុះក្រោយពីការប្រជុំនឹងប៉ុន្មានថ្ងៃ ទើបគេចាប់?

សំផាត់ : យូរគ្រាន់ដែរ ប្រហែលជាម៉ាខែជាង ។

ដារ៉ា : ចឹង ពួរិះគន់ច្រើនដង ឬក៏ម្ដង?

សំផាត់ : ទេ! ម្ដងប៉ុននោះឯង ។

ដារ៉ា : ចឹងក្រោយពីការរិះគន់ក្រោយរយៈពេលម៉ាខែ ទើបមានការចាប់ខ្លួនពូ?

សំផាត់ : បាទ!

ដារ៉ា : ហេតុអីបានគេទុកដល់យូរម៉េះ?

សំផាត់ : គេចាប់នោះ គេសរសេរដាក់ក្នុងក្រដាសនោះ គេសរសេរថាចេះ ក្រដាសគេ បញ្ហាចេញ អាមេគុកនោះហៅខ្ញុំសួរ ដល់ខ្ញុំជាប់ចូលគុកហើយ ។ ដល់មកខ្ញុំជាប់ចូលគុកហើយណា ហើយទៅដល់គុក គេហៅសួរថា *"ដែលមកជាប់គុកនេះ មានដឹងថាមានទោសអីដែរទេ?"* ខ្ញុំថា *"ខ្ញុំអត់ដឹងទេ មិនដឹងជាទោសរឿងស្អី ធំប៉ុនណាក៏ខ្ញុំអត់ដឹង"* ហើយគេសួរ

បញ្ជាក់ថា "ប្រាកដថាមិនដឹងរឿងហើយ" "អត់ដឹងទេ" ខ្ញុំប្រាប់គាត់ថា "បើសិនជាទោស នោះវាធំរហូតដល់ក្បត់បដិវត្ត ទុកក៏វាខាតបាយ ខាតបបរគេដែរ"។ បានអាប៉ិប្រធាន គុកនោះ ដកសំបុត្រពីហោប៉ៅ ហុចមកខ្ញុំ។

ដារ៉ា : កាលនឹង ប្រធានគុកនៅណា ដែលដកសំបុត្រ?

សំដាត់ : តាសឿន ឈ្មោះ តាសឿន។ ដកហុចមកនេះខ្ញុំមើល១ឃើញគេដាក់"ទោសក្បត់ បដិវត្ត"។

ដារ៉ា : ដាក់ចឹងម៉ង?

សំដាត់ : បាទ!

ដារ៉ា : សរសេរអីផ្សេងទៀតក្រៅពីពាក្យហ្នឹង?

សំដាត់ : បញ្ជាឲ្យយកឈ្មោះ ៣នាក់កាលនោះ។

ដារ៉ា : អ្នកណាខ្លះ?

សំដាត់ : កន្ទេងពេទ្យ បាទ!អាមួយឈ្មោះ យ៉េត, អាមួយឈ្មោះ នៅ, អាមួយនៅប្រាសាទ អាមួយនៅភ្នំលៀប នៅភូមិត្រយោងសព្វថ្ងៃនៅ។ ៣នាក់ខ្ញុំហ្នឹងឯង យកទៅដាក់គុក ទោសក្បត់បដិវត្ត ចាំសងឈាមជាមួយបដិវត្ត។

ដារ៉ា : ចាំអីគេ?

សំដាត់ : ចាំសងឈាម។

ដារ៉ា : ចាំសងឈាមជាមួយបដិវត្ត?

សំដាត់ : ហ្នឹង ទោសនេះធ្ងន់ដល់ហើយ។

ដារ៉ា : គេដាក់ចឹងម៉ង?

សំដាត់ : បាទ!

ដារ៉ា : ហើយនៅក្នុងសំបុត្រហ្នឹង អ្នកណាអ្នកស៊ីញ៉េ?

សំដាត់ : យាយថែម អ្នកបញ្ជា។

ដារ៉ា : ឃើញអក្សរហ្នឹងម៉ង?

សំដាត់ : យាយថែមអ្នកវៃគ្រានោះឯង ឈ្មោះគាត់តែម្ដង។

ដារ៉ា : ក្នុង៣នាក់ហ្នឹង ពូ?

សំដាត់ : បាទ!

ដារ៉ា : ក្នុងចំណោម៣នាក់ មានអ្នកនៅរស់ដែរ?

សំផាត់ ៖ ទេ! នៅទាំងអស់គ្នាទាល់ឥឡូវ ខ្ញុំមួយ អាមួយនៅភ្នំលៀប អាមួយនៅប្រសាទ នៅទាំងអស់ ។

ដារ៉ា ៖ មួយនៅភ្នំលៀបឈ្មោះអី ពូ?

សំផាត់ ៖ ឈ្មោះ នៅ ។

ដារ៉ា ៖ ឈ្មោះ នៅ?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ពូមានស្គាល់ប្រពន្ធគាត់ រាល់ថ្ងៃ?

សំផាត់ ៖ អត់ស្គាល់ទេ ។

ដានី ៖ នៅភ្នំលៀប នៅភូមិអី?

សំផាត់ ៖ នៅភូមិទ្រយោង ។

ដារ៉ា ៖ ឈ្មោះ នៅ?

សំផាត់ ៖ ភូមិទ្រយោង ឈ្មោះ នៅ ។

ដានី ៖ ឪពុកគាត់អី ស្គាល់ឈ្មោះឪពុកគាត់?

សំផាត់ ៖ អូ! ជីតាអត់ស្គាល់ទេ ។

ដានី ៖ ឪពុកម្ដាយ?

សំផាត់ ៖ អត់ទេ ។

ដារ៉ា ៖ រាល់ថ្ងៃ ហេតុអីបានពូដឹងថាគាត់រស់នៅក្នុងភូមិ?

សំផាត់ ៖ ទេ! ខ្ញុំធ្លាប់ជួបវាដែរតើ ។

ដារ៉ា ៖ យូរទេ ពូ?

សំផាត់ ៖ ខ្ញុំខានទៅប្រហែលជា២-៣ឆ្នាំហើយ ។

ដារ៉ា ៖ ភ្នំលៀបហ្នឹង?

សំផាត់ ៖ បាទ!

ដានី ៖ ឈ្មោះ នៅ ផ្ទះគាត់នៅម្ដុំណា?

សំផាត់ ៖ នៅភូមិទ្រយោង គេហៅភូមិទ្រយោង ។

ដានី ៖ នៅភូមិទ្រយោង ប៉ុន្តែផ្ទះម្ដុំណាទៅ ផ្ទះគាត់?

សំផាត់ ៖ ខ្ញុំវាភ្លេចទៅ តែសួរគេនោះដឹងហើយ ។

ដានី ៖ បាទ! ឈ្មោះ នៅ ក្រែងលរទៅ ក្រែងមានឈ្មោះ នៅ ច្រើន?

សំផាត់ ៖ នៅៗ នៅភូមិទ្រយោង ។

ដារ៉ា ៖ មាននៅ តែម្នាក់ទេ?

សំផាត់ ៖ នៅ ម្នាក់ អាមួយទៀតនៅប្រាសាទ ។ អាមួយនោះឈ្មោះស៊ីយ៉េត ខ្ញុំអត់ស្គាល់ដែរ អានោះ នៅធ្វើការកន្លែងឃុំដែរ ក្រុមប្រឹក្សាឃុំ មិនដឹងជាស្អី ។

ដានី ៖ ឈ្មោះ យ៉េត?

សំផាត់ ៖ ឈ្មោះ យ៉េត ។

ដានី ៖ ធ្វើការក្រុមប្រឹក្សាឃុំ?

សំផាត់ ៖ កាលមុនវាធ្វើការនៅនឹងកន្លែងឃុំ ប៉ុនមិនដឹងថាបោះឆ្នោតក្រោយមិនដឹងយ៉ាងម៉េច ។

ដារ៉ា ៖ ឃុំអីគេកាលនឹង?

សំផាត់ ៖ ឃុំប្រាសាទ ។

ដារ៉ា ៖ ឃុំប្រាសាទ នៅព្រះនេត្រព្រះដែរ?

សំផាត់ ៖ ស្រុកព្រះនេត្រព្រះ ។

ដានី ៖ ក្រុមប្រឹក្សាឃុំព្រះនេត្រព្រះ?

សំផាត់ ៖ ប្រាសាទៗ ។

ដានី ៖ ឃុំប្រាសាទនៅណា?

សំផាត់ ៖ ឃុំប្រាសាទនៅព្រំប្រទល់សៀមរាប ។

ដានី ៖ ស្រុកព្រះនេត្រព្រះដែរ?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ចឹងពេលចាប់មក មានឈ្មោះទាំង៣នាក់ហ្នឹង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ហើយមានជាសំបុត្រ គេចេញមក?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ដែលមានឈ្មោះពូ?

សំផាត់ ៖ ឈ្មោះខ្ញុំមួយ ។

ដារ៉ា ៖ ឈ្មោះ យ៉េត?

សំផាត់ ៖ យ៉េត ឈ្មោះ នៅ ព្រោះអានោះនៅពេទ្យជុំគ្នា ។

ដារ៉ា ៖ គាត់ទាំង២នាក់ហ្នឹង ជាពេទ្យដូចពូដែរ?

សំផាត់ ៖ បាទ! ធ្វើពេទ្យ ។

ដារ៉ា ៖ ដល់ពេលចាប់ទៅ ពូថាអានសំបុត្រហ្នឹង ឃើញត្រាយាយថែម?

សំផាត់ ៖ បាទ! ពេលខ្ញុំហុចក្រដាសនោះទៅគាត់វិញទៅ ខ្ញុំប្រាប់ថាទោសនេះដូចធ្ងន់ បើនិយាយពីរឿងសកម្មភាពដែលធ្វើ គឺខ្ញុំអត់ដឹងទេ ហើយខ្ញុំក៏មិនដែលមានគំនិតណាទៅក្បត់បដិវត្ត ។ បានអាប៉ិ ប្រធានគុកនេះថា *"បើចង់ ឯងកុំរត់ណា ។ អញនៅទៅវាមិនស្លាប់ទេ"* កុំតែរត់ ។

ដារ៉ា ៖ ចឹងពេលដែលគាត់ប្រាប់ចឹង មានរឿងរ៉ាវអីកើតឡើងអីទៀតទៅ សម្រាប់ពូពេលហ្នឹង?

សំផាត់ ៖ ទេ! គេឲ្យធ្វើការធម្មតា ដូចថាអ្នកជាប់ទោសដែលធ្វើការមិនស្រួលប៉ុន្មានទេ ស៊ីមិនឆ្អែតផង ។

ដារ៉ា ៖ ហើយជាប់ទោសហ្នឹង ត្រូវជាប់ខ្នោះ ជាប់អីដែរ?

សំផាត់ ៖ អត់ទេ! អត់ដែលជាប់ខ្នោះទេ ទៅនៅដូចធម្មតា ដូចយើងរោងចេះឯង កន្លែងគេចេះ ។

ដារ៉ា ៖ ពូថាគុកហ្នឹងសង់ជារោង?

សំផាត់ ៖ បាទ! សង់ជារោងទេ គេហៅមន្ទីរកសាង ។

ដារ៉ា ៖ មន្ទីរកសាងស្អីគេកាលហ្នឹង?

សំផាត់ ៖ មន្ទីរកសាងអ្នកដែលខុស ។

ដារ៉ា ៖ អ្នកដែលខុស?

សំផាត់ ៖ បាទ!

ដានី ៖ ឈ្មោះអី?

សំផាត់ ៖ អាហ្នឹងគេហៅគុកភ្នំទ្រយោង ។

ដារ៉ា ៖ គុកភ្នំទ្រយោង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ អាហ្នឹងឈ្មោះពូក្រោយ ឬក៏?

សំផាត់ ៖ ទេ! ឈ្មោះ តាំងពីដើមមកគេដាក់គុកភ្នំទ្រយោងបណ្តោយ គុកតំបន់គេ ។

ដារ៉ា ៖ ចុះអាគុកហ្នឹង មានមកតាំងពីពេលណាមក?

សំផាត់ ៖ គុកហ្នឹងដូចជាកើតមិនយូរប៉ុន្មានទេ គុកហ្នឹងកើតមុនខ្ញុំទៅជាប់ប្រហែលជា២ខែក៏មិនដឹង ។

ដានី ៖ ពីណាអ្នកបង្កើត?

សំផាត់ ៖ យាយថែម ។

ដារ៉ា ៖ ម៉េចបានពូដឹងថា យាយថែមអ្នកបង្កើត?

សំផាត់ ៖ យាយថែមគាត់ចៅហ្វាយស្រុក គាត់អ្នកគ្រប់គ្រងនោះឯង ។

ដារ៉ា ៖ បើតាមសួរទៅ កាលពីកន្លែងយាយថែម ទៅគុកហ្នឹងឆ្ងាយទេ ពូ?

សំផាត់ ៖ មិនជាឆ្ងាយប៉ុន្មានទេ ចេញពីភ្នំលៀបមក យើងមើលមកមិនឃើញភ្នំមើលត្បូង ភ្នំលៀប នៅជាប់នឹងភូមិ អាភ្នំខាងត្បូងនោះឯង ។ ដីប្រហែលជា២គីឡូ ។

ដារ៉ា ៖ ចុះពូជាប់នៅហ្នឹង គេឲ្យពូធ្វើការអីនៅក្នុងគុក?

សំផាត់ ៖ ទៅដំបូងគេឲ្យដាំចេក ក្រោយពីដាំចេក គេឲ្យគាស់ដំបូកៗដែលមានដើមឫស្សី មានដើមស្វាយ គេឲ្យយើងគាស់រំលាយវាឲ្យទៅជាដីស្មើ ។

ដារ៉ា ៖ ហើយក្រោយមក ម៉េចទៀត ពូ?

សំផាត់ ៖ ដល់ក្រោយមកទៅ ប្រហែលជារយៈជិតម៉ាខែ គេឲ្យឈប់ ។

ដារ៉ា ៖ ឲ្យឈប់ទៅធ្វើការងារចឹងៗ?

សំផាត់ ៖ ឲ្យឈប់ធ្វើការ គាត់ឲ្យមកនៅជិតគាត់ ។

ដារ៉ា ៖ នៅគៀកហ្នឹងគាត់ម៉ង?

សំផាត់ ៖ បាទ!

ដារ៉ា ៖ គៀកនឹងតាសឿនហ្នឹង?

សំផាត់ ៖ បាទ! បានៗរស់ ដោយសារចឹងឯង កុំអីមិនត្រូវរស់ទេ បើសិនជាគេមិនវៃចោលក៏ងាប់ហ្នឹងអត់បាយ ។

ដារ៉ា ៖ ហើយការនៅក្នុងគុកហ្នឹង ពូការហូបចុកអីយ៉ាងម៉េចទៅ?

សំផាត់ ៖ ហូបចុក គេចែករបប អាចានត្រប៉ែតយើងនេះ គេវាស់ឲ្យត្រឹមម៉ារង្វន់ មិនហៀរទេ ត្រឹមតែរង្វន់ គិតទៅ២វែកកំបង់នេះ ។

ដារ៉ា ៖ ជាបាយ ឬជាបបរ?

សំផាត់ ៖ ហីបបររាវទៀត ។

ដារ៉ា ៖ ហើយហូបជាមួយអី?

សំផាត់ ៖ ម្ហូបជួនកាលអំបិល ជួនកាលមានសម្លអីខ្លះ ហើយយើងស៊ីម៉េចឆ្អែត មាឌប៉ុនៗណាណេះ ។

ដារ៉ា ៖ ចុះការហូបចុកចឹង រយៈពេលវែង ឬក៏មានការហូបចុក ប្រសើរជាងនឹងក្រោយមក?

សំដាត់ ៈ ខ្ញុំនៅក្រោយមក គាត់ឲ្យហូបបាយដូចថាធម្មតា ។ ពួកអ្នកដែលជាប់ផ្សេងៗ នៅតែចឹង ឯង ។

ដារ៉ា ៈ ពេលដែលពូទៅដល់ឃើញអ្នកជាប់គុកច្រើន?

សំដាត់ ៈ កាលខ្ញុំទៅដល់ដំបូងប្រហែលជាមិនដល់១០០នាក់ ដល់ក្រោយមកបានច្រើន រយៈពេល ម៉ាខែជាង ចូល២ខែ ចាប់ច្រើន ប្រហែលជាចង់១០០០គ្រួសារជាង ។

ដារ៉ា ៈ ទៅណា?

សំដាត់ ៈ ទៅនៅធ្វើរោងនៅធម្មតា ។

ដារ៉ា ៈ ហើយចេញទៅធ្វើការអីយ៉ាងម៉េច?

សំដាត់ ៈ ធ្វើការដូចតែនៅសហករណ៍ដែរ ប៉ុនដូចថាក្នុងគុកវាអត់មានជញ្ជាំង វាពិបាកជាងអាគុក មានជញ្ជាំង ។ ដូចថារាល់ថ្ងៃធ្វើការដីប៉ុននេះចេះ អត់មានឲ្យដើរចេញទេ ។

ដារ៉ា ៈ ហើយមានជាឈ្លបគេ?

សំដាត់ ៈ មានយោធាគេយាម ដើរចេញ សុទ្ធតែត្រូវជំបង ។

ដារ៉ា ៈ ធ្លាប់មានអ្នករត់ដែរ?

សំដាត់ ៈ មានខ្លះដែររត់ ហើយខ្លះក៏រត់រួចទៅ ហើយខ្លះក៏រត់ហើយចាប់បានវិញទៅ ។

ដារ៉ា ៈ អាចាប់បានវិញគេធ្វើម៉េច?

សំដាត់ ៈ អាចាប់បានវិញ ដឹងតែងាប់ហើយ ។

ដារ៉ា ៈ ស្លាប់ម៉ង?

សំដាត់ ៈ បាទ! ស្លាប់ហើយ ។

ដារ៉ា ៈ ស្លាប់ដោយបាញ់ពេលកំពុងរត់ ឬក៏វៃចោល?

សំដាត់ ៈ ស្លាប់បាញ់ចោល បើសិនជាគេតាមទាន់កំពុងរត់ក៏គេបាញ់ បើសិជាគេចាប់បានមកនៅ រស់គេយកមកវៃចោល ។

ដារ៉ា ៈ វៃនៅម្តុំណា?

សំដាត់ ៈ វៃច្រើនកប់នៅខាងជើងភ្នំ ។

ដារ៉ា ៈ ខាងជើងភ្នំ?

សំដាត់ ៈ បាទ! ប៉ុនដល់ក្រោយមក គេបង្កើតកន្លែងដាក់ខ្មោះមួយនៅខាងជើង អានោះគេដាក់ ចំណុះបានប្រហែលជិត១០០នាក់ ។

ដារ៉ា ៈ ខ្មោះរូបរាងម៉េច ដាក់ម៉េច?

សំផាត់ ៖ ដាក់ខ្នោះជើង ។

ដារ៉ា ៖ ខ្នោះជើង?

សំផាត់ ៖ ដូចថាអ្នកដែលគេបញ្ជូនទៅថាវាទោសធ្ងន់ទៅគេយកទៅដាក់ខ្នោះ ។ ដល់ថ្ងៃគេយកទៅវ៉ៃចោល ។

ដារ៉ា ៖ ដល់ថ្ងៃគេយកទៅវ៉ៃចោល?

សំផាត់ ៖ បាទ!

ដារ៉ា ៖ ហើយអឺ! ចុះគ្នាដែល២នាក់ទៀត ដែលទៅជាមួយពូ គេឲ្យធ្វើអី?

សំផាត់ ៖ កាលនោះ ដល់ក្រោយមក គេបំបែក ខ្ញុំគេឲ្យនៅកន្លែង ២នាក់ឲ្យទៅធ្វើនេសាទ ធ្វើអាជីវកម្ម ។

ដារ៉ា ៖ នៅក្នុងគុកហ្នឹងដែរ?

សំផាត់ ៖ ទេ! គេឲ្យចេញទៅក្រៅហើយ ទៅរកត្រីខាងក្រៅ ។

ដារ៉ា ៖ សម្រាប់ផ្គត់ផ្គង់កន្លែងគុកហ្នឹង?

សំផាត់ ៖ សម្រាប់ផ្គត់ផ្គង់កន្លែងគុក ។

ដារ៉ា ៖ ចឹងសល់តែពូទេ នៅជាប់?

សំផាត់ ៖ បាទ! នៅកន្លែង នៅតែខ្ញុំ ២នាក់នោះគេទៅរកត្រី គេហៅធ្វើអាជីវកម្ម ។

ដារ៉ា ៖ ចុះពេលដែលមក ដែលពូក្រោយមកដែលមានជាប់គុកនឹង រាប់ពាន់គ្រួសារ មកនឹង មកមានទាំងក្មេង មានទាំងចាស់ ទាំងប្រុស ទាំងស្រី?

សំផាត់ ៖ បាទ! ជួនកាលមកទាំងគ្រួសារ ដូចថាម៉ាគ្រួសារដែលខុសទៅ គេបញ្ជូនគ្រួសារចូលមក ។

ដារ៉ា ៖ ចូលកន្លែងហ្នឹង?

សំផាត់ ៖ ចូលកន្លែងហ្នឹង ។

ដារ៉ា ៖ ហើយអឺ! ដូចថាមានរលួសមនុស្សអីចេញពីកន្លែងគុកហ្នឹង ដូចថាជាចំនួនអីត្រូវបាត់តិចម្តងៗ?

សំផាត់ ៖ អូ! បើរឿងគេសម្លាប់ ខ្ញុំស្មានមើល ក្នុងម៉ាយប់ក៏ត្រូវស្លាប់២នាក់ អានោះជាភាគរយដូចថាជាមធ្យមវាមានជួនកាលដល់១០នាក់ ជួនកាល៥នាក់ ជួនកាល៣នាក់ ២នាក់ បើគេមិនវ៉ៃចោលទេ ក៏ស្លាប់ដោយសារអត់បាយដែរ ។

ដារ៉ា ៖ ចុះភាគច្រើនស្លាប់ដោយអត់បាយ ឬក៏ស្លាប់ដោយសម្លាប់?

សំផាត់ : វាចង់ប្រហែលគ្នា បើតាមគិតមើល ព្រោះវាមិនដែលអត់មានយប់ណា ថាអត់មានសម្លាប់ ។

ដារ៉ា : ម៉េចបានពូដឹងចឹង?

សំផាត់ : ចុះបើខ្ញុំនៅកន្លែង អាប្រធានគុក ។

ដារ៉ា : ចុះពេលយកចេញ យកចូល?

សំផាត់ : ពេលគេយកចេញ គេយកអាផ្លូវនោះឯង ដែលចេញទៅខាងជើង ។

ដារ៉ា : ពេលយកចេញទៅ?

សំផាត់ : បាទ!

ដារ៉ា : ចឹងពូឲ្យតែយកអ្នកទោសទៅសម្លាប់ចេញទៅសម្លាប់ ឬក៏អ្នកទោសស្លាប់នៅក្នុងគុកហ្នឹងពូដឹង?

សំផាត់ : បាទ! ដឹង ឃើញគេ យើងនៅនោះហើយយើងចេះតែឃើញ ។ មានពេលខ្លះ វាច្រើនទៅគេហៅទៅជួយជីកអន្លុងគេ ។

ដារ៉ា : ធ្លាប់បានជីកអន្លុងគេ?

សំផាត់ : ធ្លាប់ ។

ដារ៉ា : អន្លុងនៅកន្លែងណា ចំហៀងខាងណាអីខាងណៃ?

សំផាត់ : ខាងជើង ។

ដារ៉ា : ខាងជើងភ្នំហ្នឹង?

សំផាត់ : កាលនោះវាអស់គ្នាទៅ គេមិនដឹងទៅរកណា គេហៅទៅជួយជីកគេទៅ គ្រាន់ថាយើងចិត្តមិនឃោឃៅ ក៏មិនដែលបានទៅជួយវ៉ៃគេដង ។

ដារ៉ា : ជីកហ្នឹង ធ្លាប់ចូលរួមជីករណ្តៅប៉ុន្មានដង?

សំផាត់ : ជីកអន្លុងរួច ក៏ដើរចេញមកវិញមក ។

ដារ៉ា : អន្លុងដែលពូធ្លាប់ជីកទំហំប៉ុនណា?

សំផាត់ : ជីកប្រហែលជា៨-៩ដង ជីកអាចុងក្រោយនេះធំ វាចូល៩០នាក់ជាង ។

ដារ៉ា : មនុស្សហ្នឹង?

សំផាត់ : បាទ!

ដារ៉ា : ដាក់មួង?

សំផាត់ ៖ ម៉ាគុកដែលខ្ញុំប្រាប់ ។ អានោះពួសន្ធឹកថាវៀតណាមចូលហើយ អាជិតចប់ហើយ អានោះ ជីកអន្លុងធំ អន្លុងប្រហែលប៉ុនម៉ារោង ជីកទៅពេលល្ងាច ម៉ោង១២ គ្នា៥នាក់ ។

ដារ៉ា ៖ ទទឹងប៉ុន្មាន បណ្ដោយប៉ុន្មាន?

សំផាត់ ៖ ប្រហែលជាប៉ុននេះ អន្លង់នេះប្រហែលជាប៉ុននេះ ។

ដារ៉ា ៖ អាចថា៣ម៉ែត្រ?

សំផាត់ ៖ ហៅថាចូល៣ម៉ែត្រ ៤ជ្រុង ។

ដារ៉ា ៖ ហើយជម្រៅវា?

សំផាត់ ៖ ជម្រៅប៉ុននេះ ។

ដារ៉ា ៖ ដល់ត្រឹមទ្រូង?

សំផាត់ ៖ ម៉ាម៉ែត្រជាង ។

ដារ៉ា ៖ ម៉ាម៉ែត្រជាង?

សំផាត់ ៖ បាទ! ដាក់ទៅពេញ ។

ដារ៉ា ៖ បានសម្លាប់មែន ក្នុងរណ្ដៅហ្នឹង?

សំផាត់ ៖ វៃចោលទាំងអស់ ខ្ញុំអង្គុយមើល ។

ដារ៉ា ៖ អង្គុយមើលតែគេវៃ?

សំផាត់ ៖ អង្គុយមើលតែគេវៃនោះឯង ។

ដានី ៖ ពីណាអ្នកវៃ?

សំផាត់ ៖ អាហ្នឹងពួកយោធា ។

ដានី ៖ ស្គាល់ឈ្មោះខ្លះ?

សំផាត់ ៖ អូ! អត់ស្គាល់ទេ ។

ដារ៉ា ៖ ពេលវៃហ្នឹង អត់មានវត្តមានអ្នកណាទៀត?

សំផាត់ ៖ មានតែយោធាដែលនៅការពារគុក៣០នាក់នោះឯង អ្នកវៃ ។

ដារ៉ា ៖ ហើយចុះតាសឿនអី?

សំផាត់ ៖ តាសឿន គេអ្នកបញ្ជា គេដែលទៅ ។

ដារ៉ា ៖ អត់មានទៅអង្គុយមើលនៅហ្នឹង?

សំផាត់ ៖ អត់ទេ ។

ដានី ៖ គេយកអីខ្លះមកវៃហ្នឹង?

សំផាត់ ៖ ហេ៎! វៃនេះគ្មានស្អី មានដំបង មានចបកាប់ ។

ដានី ៖ ដូចរបៀបថា គេវៃហ្នឹងគេឲ្យយើង?

សំផាត់ ៖ គេឲ្យយើងអង្គុយហើយ ខ្ញុំឃើញ ១០នាក់ចឹងគេឲ្យអង្គុយតាមមាត់អន្លង់ ។ ដូចថាអន្លង់គេមកខាងនេះ គេឲ្យអង្គុយបែរមុខមកអន្លង់ ដៃវាជាប់ចំណងចេះ ឲ្យយើងអង្គុយកលុតជង្គង់ អាខ្លះក៏អង្គុយខាងនោះ អានេះអង្គុយខាងនេះ ដើរវៃពីក្រោយ ។

ដារ៉ា ៖ ដើរវៃម៉ាជួរចឹងម៉ង?

សំផាត់ ៖ វៃយកតែអានេះ ។

ដារ៉ា ៖ ហើយវៃទាំងជាប់ចំណង?

សំផាត់ ៖ ជាប់ចំណងទាំងអស់ មាំុងភ្លាក់ៗ យកមកម៉ាជួរទៀតមកដាក់វៃទៀតទៅ ។ វៃកាលនោះបើប្រុសៗមានខោស្លៀក បើស្រីៗអត់មានទេ ស្រីៗ១០នាក់ អត់មានខោអាវ គឺស្រាតទាំង អស់ ។

ដារ៉ា ៖ សាហាវ ពូ?

សំផាត់ ៖ បើខែភ្លឺៗ អង្គុយមើលពី...មកឃើញច្បាស់ ។

ដារ៉ា៖ វៃចឹងមានស្រែកដែលពូ?

សំផាត់ ៖ មានស្រែកអីផង ។

ដានី ៖ អ្នកទោសដែលគេមុនវៃហ្នឹងអ្នកហ្នឹងមានស្រែកទេ?

សំផាត់ ៖ វាកម្រសូវមានស្រែកដូចថាវាងាប់ហើយខ្និល ។

ដារ៉ា ៖ ចឹងអ្នកទោសដូចជាបណ្តោយតាមវាសនា?

សំផាត់ ៖ ចុះមិនដឹងរើរទៅណារួច បើយោធានៅហឹផ្ទុំទាំងអស់មិនដឹងជារត់ទៅណារួច ។

ដានី ៖ មានកាំភ្លើងដែលយោធាហ្នឹង?

សំផាត់ ៖ មានកាំភ្លើងណា ពួកការពារគុក ។

ដារ៉ា ៖ ពេលវៃអីពួកយោធាហ្នឹងវាមានស្រែកនិយាយថាយ៉ាងម៉េចទេពូ?

សំផាត់ ៖ អារឿងចុះវាមានស្រែកវាសប្បាយគេ ថាគេបានសម្លាប់មនុស្ស ។

ដារ៉ា៖ មានដែលស្រែកជេរថាយ៉ាងម៉េចៗទេពូ?

សំផាត់ ៖ កាលដែលសម្លាប់អាចុងបង្អើយនេះមានស្រីម្នាក់ស្រែក ខ្ញុំគ្រាន់តែចាំបានថាមានស្រីម្នាក់វាស្រែកថា ស្លាប់ចុះបដិវត្តអើយយើងខ្ញុំមិនស្តាយទេ មួយម៉ាត់ប៉ុណ្ណឹងឯង ។

ដារ៉ា ៖ ចឹងមានន័យអ្នកហ្នឹងឯងបានបំរើក្នុងជួរបដិវត្តដែលចឹង ហីយ៉ាងម៉េច?

សំផាត់ ៖ ពួកនោះដែលគេយកមកនោះ គេយកពីកងចល័តធ្វើពេទ្យខ្វះអីខ្វះ ។

ដារ៉ា ៖ នារីហ្នឹង?

សំផាត់ ៖ បាទ ។

ដារ៉ា៖ ហើយសម្លាប់ហ្នឹងមានខោអាវដែរ?

សំផាត់ ៖ អត់មានទេ ស្រាត់អស់ម៉ង ។

ដានី ៖ មានគេរំលោភទេ មុនហ្នឹងសម្លាប់?

សំផាត់ ៖ អត់ដឹងទេ ព្រោះយើងមិនបានទៅជិតកន្លែងគុកគេទេ យើងដឹកតែអន្ទងយើងនៅអែប អន្ទងហ្នឹងហើយ ។

ដារ៉ា ៖ យ៉ាងម៉េចបានជាវាទុកចិត្តពូ ឲ្យឃើញការសម្លាប់អីចឹង?

សំផាត់ ៖ ឲ្យទៅដោយសារ តា សឿននេះ គាត់យកខ្ញុំទៅនៅអែបគាត់ទៅ ចេះតែហៅប្រើទៅ ។

ដារ៉ា ៖ ចឹងហៅប្រើពូ?

សំផាត់ ៖ ដូចថាការងារវាច្រើនទៅ វាធ្វើអត់ទាន់ទៅគេហៅទៅជួយគេទៅ ។

ដារ៉ា ៖ ពូមានធ្លាប់ជួយចូលរួមធ្វើបញ្ជីរ ធ្វើអីដែរ?

សំផាត់ ៖ អត់ទេ ។

ដារ៉ា ៖ មានអ្នកណាជាអ្នកធ្វើបញ្ជីរកាលហ្នុង?

សំផាត់ ៖ ធ្វេបញ្ជីរមានគ្នាគេផ្សេង យើងនៅជាប់ទោសដែលនៅ ប៉ុនការងារបន្តិចបន្តួចគេចេះតែឲ្យ យើងធ្វើទៅ ។

ដារ៉ា ៖ ពូមានធ្លាប់ព្យាបាលអ្នកទោសនៅក្នុងហ្នឹងទេ?

សំផាត់ ៖ អ្នកទោសនោះបើព្យាបាល ព្យាលបាលតាមរបៀបបុរាណ ។

ដារ៉ា ៖ យ៉ាងម៉េចទៅពូ?

សំផាត់ ៖ បុរាណយើងដាំទឹកថ្នាំអីណា ឬក៏ធ្វើជាកន្ទក់ដាក់ស្ករអី មេគុករឯងសួរខ្ញុំចេះថា អ្នក ដែលមកជាប់ហើមនេះធ្វើម៉េចបានបាត់ ខ្ញុំនឹកឃើញថាបើបានកន្ទក់មកនិងស្ករទៅវាបាន ឆ្អែតជងវា វាបាត់ជងណា ខ្ញុំក៏ចេះតែថាទៅ ។

ដារ៉ា ៖ បានធ្វើ! អនុវត្តតាមចឹងទេ?

សំផាត់ ៖ មានថាម៉េច យកកន្ទក់មកដាក់ស្ករមួយថង់ពីរថង់កកូរលាយគ្នាទៅចែកបបរស្ករឲ្យស៊ីទៅ ទៅរកដើមឫស្សីស្រុកឫស្សីព្រៃចេះស្ងោកដាក់ទៅៗឲ្យគ្នាបានឆ្អែតៗទៅ ព្រោះយើងជា អ្នកជាប់គុកដូចគ្នា ។

ដារ៉ា ៖ ពូមួយរយៈពេលដែលពូជាប់គុកនៅហ្នឹងបានធ្លាប់ឃើញទាំងការសម្លាប់អីចឹងអីពូហើយអ្នកស្លាប់ក្នុងគុកអីចឹងមួយរយៈហ្នឹងពូដែលឃើញយាយថែមទៅកន្លែងហ្នឹងទេ?

សំផាត់ ៖ ធ្លាប់ទៅដែរយាយថែម ។

ដារ៉ា ៖ ធ្លាប់ទៅ?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ កាលដែលធ្លាប់ទៅហ្នឹងប៉ុន្មានដងអីប៉ុន្មានដងពូមានបានចាំទេ?

សំផាត់ ៖ ខ្ញុំឃើញដូចជាទៅមួយដង បើមុនៗខ្ញុំមិនដឹងទេ ។

ដារ៉ា ៖ មួយរយៈពេលពូជាប់គុក?

សំផាត់ ៖ ដូចថាខ្ញុំមិននៅអី ។

ដារ៉ា ៖ បាទ ។

សំផាត់ ៖ ទៅជួបគាត់តែម្តងឃើញគាត់ទៅ ។

ដារ៉ា ៖ គាត់ទៅជួបអ្នកណា?

សំផាត់ ៖ ជួបតា សឿនហ្នឹង ។

ដារ៉ា ៖ ពេលជួបតាសឿនហ្នឹងពូនៅណា?

សំផាត់ ៖ គេដែលឲ្យនៅជិត ។

ដារ៉ា ៖ ចឹង! តែគ្រាន់បានដឹងថា យាយថែមបានទៅជួបតាសឿនហ្នឹង?

សំផាត់ ៖ ចូលទៅអង្គុយយើងដើរចេញ យើងដែលនៅ ។

ដានី ៖ ពូមានចាំថា យាយថែមទៅគាត់មានជិះអីទៅមានគ្នាប៉ុន្មាននាក់ដែលទៅជួបហ្នឹង?

សំផាត់ ៖ ជួនកាលគាត់ជិះម៉ូតូទៅ ច្រើនជិះម៉ូតូ ។

ដារ៉ា ៖ មានអ្នកឌុបឬមួយយ៉ាងម៉េច?

សំផាត់ ៖ មានអ្នកឌុបជានិរសាគាត់ ។

ដារ៉ា ៖ ប្រុសឬស្រី?

សំផាត់ ៖ ប្រុស ។

ដានី ៖ ជិះម៉ូតូយ៉ាងម៉េចម៉ូតូគាត់?

សំផាត់ ៖ ម៉ូតូ«សេអិល» ។

ដានី ៖ ម៉ូតូ«សេអិល»ពណ៌អីទៅ?

សំផាត់ ៖ សេអិលពណ៌«ស» ធុងសាំង«ស» ។

ដារ៉ា ៖ យាយថែមដែលថា ទៅជួប តា សឿន ប្រធានគុកហ្នឹងណា ពេលទៅជួបហ្នឹងទៅជួបមុន ព្រឹត្តិការដែលការសម្លាប់ថាពួយើញជីកអន្លុងធំអីហ្នឹង មុនឬក្រោយ?

សំផាត់ ៖ មុន! អាសម្លាប់នោះ សម្លាប់រួចបានមួយថ្ងៃរត់បណ្ដោយ ព្រោះវៀតណាមចូលហើយនោះ ។

ដារ៉ា ៖ ចឹង?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងមុនៗមុនហ្នឹងទៀតមានការសម្លាប់ទេ?

សំផាត់ ៖ មុនហ្នឹងទៀតខ្ញុំអត់ដឹងទេ ថាយាយថែមទៅជួប ដឹងថាគាត់ទៅម្ដងមុនអាសម្លាប់គ្នាច្រើនហ្នឹង ។

ដារ៉ា ៖ ទៅមុនរយៈពេលយូរទេពូ?

សំផាត់ ៖ មិនជាជាយូរប៉ុន្មានទេ ប្រហែលជាបួនដប់ថ្ងៃអី ។

ដារ៉ា ៖ បួនដប់ថ្ងៃទេ?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងមានន័យថា យាយថែមទៅកន្លែងហ្នឹងដែលចឹង?

សំផាត់ ៖ ទៅ! គាត់មេគុកនោះដែលតើ ព្រោះគាត់ជាបញ្ញាតា សឿននោះហើយ ។

ដារ៉ា ៖ ចឹងម៉ារស់នៅក្បែរតា សឿនមកហ្នឹងពូមានដែលដឹងថា តា សឿនរអូរទាំពីរឿងការសម្លាប់ពីរឿងការបញ្ញាពីលើអីទេ?

សំផាត់ ៖ ទេ ដូចជាមិនដែលឮសូរនិយាយអីផង ព្រោះការងារគេមិនដែលឲ្យយើងដឹងអីផង ។

ដារ៉ា ៖ ក្រែងឮសូរគាត់ថា គាត់ហត់នឿយរឿងបញ្ញាឲ្យសម្លាប់អីចឹងពូ?

សំផាត់ ៖ មិនដែលដឹងទេ ព្រោះគេប្រជុំគេមិនដែលប្រជុំជិតនោះទេ គេមានកន្លែងគេផ្សេង ការងារអីគេនិយាយកន្លែងផ្សេងទៅ គេដែលឲ្យយើងដឹងទេ ។

ដារ៉ា ៖ ចឹងស្ថានភាពកន្លែងគុកពេលយាយថែមទៅជួបតា សឿនហ្នឹងស្ថានភាពគុកហ្នឹងយ៉ាងម៉េចដែរ ស្ថានភាពហ្នឹងវានៅយ៉ាប់យឺនឬយ៉ាងម៉េចប្រជាជនអ្នកទោសមកហ្នឹងជាប់ច្រើនឬយ៉ាងដែលកាលយាយថែមទៅជួប តាសឿនហ្នឹង?

សំផាត់ ៖ កាលនោះច្រើនហើយប្រហែលជាពាន់គ្រួសារហើយ ។

ដារ៉ា ៖ ពេលយាយថែមទៅហ្នឹង?

សំផាត់ ៖ បាទ!អានេះយើងនិយាយតែគ្រួសារមនុស្សម្នាយើងមិនដឹងជាប៉ុន្មានទេ បើគ្រួសារវាចូលពាន់ហើយ ព្រោះវានៅច្រើនពេកហើយ ។

ដារ៉ា ៖ ពេលយាយចែមទៅជួបតា សឿនហ្នឹងគាត់មានបានក្រឡេកមើលឃើញអ្នកទោសនៅក្នុងហ្នឹងដែលពូ?

សំផាត់ ៖ និយាយមិនឃើញយ៉ាងម៉េចសើច... បើនៅជុំវិញនោះហើយ ។

ដារ៉ា ៖ ចឹងពេលហ្នឹងពូមានសង្កេតឃើញអ្នកទោសអី ពេលឃើញយាយចែមចឹងមានការភ័យខ្លាចឬញ្រាក់ញ័រយ៉ាងម៉េចដែលទេ?

សំផាត់ ៖ ដែលហ៊ានទៅមើលមុខគេ សម័យលិទ្ធិផ្ដាច់ការដែលហ៊ាន ដើរតែគេច ។

ដារ៉ា ៖ ចឹងយាយចែមគាត់ទៅកន្លែងគុកហ្នឹងញឹកញាប់ដែលពូ?

សំផាត់ ៖ ទេ! ខ្ញុំឃើញតែម្ដងប៉ុណ្ណោះឯង បើក្រៅពីនោះទៀតខ្ញុំមិនបានដឹងទេ ។

ដារ៉ា ៖ កាលយាយចែមទៅគាត់ស្លៀកពាក់យ៉ាងម៉េច?

សំផាត់ ៖ ស្លៀកពាក់ខ្មៅ ។

ដារ៉ា ៖ ស្លៀកពាក់ខ្មៅមានបង់កក្រមាទេ?

សំផាត់ ៖ មាន ។

ដារ៉ា ៖ មានបង់កក្រមា?

សំផាត់ ៖ គេមិនដែលចោលទេ ។

ដារ៉ា ៖ គាត់ស្លៀកខោឬមួយស្លៀកសំពត?

សំផាត់ ៖ សំពត់ខ្មៅអាវខ្មៅក្រមាបង់ក ។

ដារ៉ា ៖ ទៅសំដៅទៅជួបតា សឿនហ្នឹងតែម្ដង?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងពេលដែលគាត់ទៅ! យាយចែមមានឃើញពូដែលពេលហ្នឹង?

សំផាត់ ៖ ទេ! មិនដឹងជាគាត់ឃើញឬមិនឃើញទេ ព្រោះខ្ញុំអង្គុយនៅឆ្ងាយដែរ ។

ដារ៉ា ៖ ព្រោះថា បើឃើញពូទៅ ព្រោះយាយចែមគាត់ជាអ្នកបញ្ជាចេញសំបុត្រមកឲ្យចាប់ពូទៅដាក់គុកភ្នំទ្រយោងហ្នឹង បើសិនជាយាយចែមទៅដល់កន្លែងហ្នឹង បើគាត់ឃើញពូ ក្រែងលោគាត់សួរតា សឿនថាហេតុអីថាពូនៅរស់ទៀត ឬក៏អត់ទាន់សម្លាប់អីចឹង ឧទាហរណ៍?

សំផាត់ ៖ រឿងហ្នឹងខ្ញុំក៏មិនដឹងដែរ ប៉ុន្តែក្រោយមកខ្ញុំដាប់បានរយៈពេលមួយខែជាង តា សឿនហ្នឹងប្រើខ្ញុំទៅផ្ទះយាយ ចែម ។

ដាវ៉ា ៖ ចឹងប្រើទៅផ្ទះយាយថែមទៀត?

សំផាត់ ៖ មិនដឹងថាទៅប្រើទៅធ្វើអី កាលហ្នឹងខ្ញុំក្មេងទៅ ប្រើទៅ យាយថែមឃើញគាត់ធម្មតាទៅ គាត់សួរនាំថា មិត្តឯងទៅណា មានការអី កាលនោះខ្ញុំមានដឹងថាគា សឿនប្រើឲ្យទៅធ្វើអីខ្ញុំមានបានចាំទេ ។

ដាវ៉ា ៖ កាលហ្នឹងប្រើពូមានឲ្យពូកាន់អីទៅទេ?

សំផាត់ ៖ មិនដឹងថា ប្រើដូចថាជាយកម៉ាស៊ីតទៅឲ្យឡានក៏មិនដឹង ។

ដាវ៉ា ៖ ចឹងមិនដឹងថាកាន់អីទៅទេ?

សំផាត់ ៖ ដូចជាកាន់ម៉ាស៊ីតពីរដប ។

ដាវ៉ា ៖ យ៉ាងម៉េចបានជាម៉ាស៊ីតមាននៅកន្លែងគុកហ្នឹងវិញ?

សំផាត់ ៖ ព្រោះឡាននោះត្រូវដឹកឈើទៅធ្វើផ្ទះឲ្យពួកអ្នកទោស ព្រោះឡានហ្នឹងវាខ្វះម៉ាស៊ីត គាត់ប្រើឲ្យយកម៉ាស៊ីតទៅឲ្យ យកម៉ាស៊ីតទៅឲ្យនៅផ្ទះយាយថែម ។

ដាវ៉ា ៖ បានទៅប៉ុន្មានដងដែរ?

សំផាត់ ៖ បានទៅតែម្តងទេ ។

ដាវ៉ា ៖ ហើយបានជួបយាយថែមទេ?

សំផាត់ ៖ ទៅផ្ទះយាយថែម ។

ដាវ៉ា ៖ ចឹងនៅពេលជួបយាយថែម យាយថែមអត់មានថាអីទេចឹង?

សំផាត់ ៖ មិនពូនិយាយថាអី គ្រាន់តែសួរថា មិត្តឯងមករកអី គ្រាន់តែប្រាប់គាត់ថា របស់នេះយកមកឲ្យទៅ យើងត្រឡប់មកវិញទៅ ។

ដាវ៉ា ៖ កាលចាប់ទៅប្រមាឹតសុទ្ធតែថា ជនក្បត់បដិវត្តហើយថា ឈាមសងបដិវត្តអីម៉េច?

សំផាត់ ៖ មិនដឹងថាគេ និយាយគ្នាគេយ៉ាងម៉េចទេ បានជាខ្ញុំអាចនៅបានខ្ញុំអត់ដឹងទេ បើសិនជាទោសដូចក្នុងក្រដាសខ្ញុំវាមិនមានពេលមកនិយាយលេងនេះដែរ ។

ដាវ៉ា ៖ យាយថែមជាអ្នកស៊ីញ៉ូ អ្នកវៃត្រាខ្លួនឯងហើយ ដែលឃើញពូមកហើយគាត់អត់មានឆ្ងល់ទេ ចឹងនៅពេលដែលពូមកជួបគាត់ហ្នឹង?

សំផាត់ ៖ រឿងគេឆ្ងល់នោះវាមិនដឹងដែរ មិនដឹងជាគេនិយាយគ្នាគេយ៉ាងខ្ញុំអត់ដឹងដែរ ព្រោះតាសឿនខ្ញុំធ្លាប់ស្គាល់គាត់ពីមុនខ្ញុំជាប់គុកដែរ ។

ដាវ៉ា ៖ គាត់ធ្វើអីតា សឿន?

សំផាត់ ៖ គាត់ប្រធានចល័ត ។

ដានី ៖ ប្រធានចល័តនៅណា?

សំផាត់ ៖ ចល័តនៅអូរលៀប ។

ដារ៉ា ៖ អូរលៀប?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងគាត់ប្រធានចល័តតាំងពីនៅអូរលៀបហ្នឹង?

សំផាត់ ៖ បាទ!ដល់ក្រោយមកបានគាត់មកនៅប្រធានគុក ។

ដានី ៖ ប្រធានចល័តអូរលៀបហ្នឹងជាប្រធានចល័តរបស់ឃុំឬមួយរបស់ស្រុក?

សំផាត់ ៖ កាលនោះចល័តរបស់ស្រុក ។

ដានី ៖ ស្រុកណា?

សំផាត់ ៖ ស្រុកព្រះនេត្រព្រះហ្នឹង ។

ដារ៉ា ៖ ចឹងសឿនហ្នឹងមិនមែនជាអ្នកនៅព្រះនេត្រព្រះហ្នឹងទេ?

សំផាត់ ៖ អត់ទេ អ្នកនៅភ្នំពេញអ្នកមកពីនិរតីពួកក្រុមយាយថែម ។

ដារ៉ា ៖ ដល់ពេលក្រោយមកពូទៅកន្លែងគុកតា សឿនហ្នឹងគាត់ជា?

សំផាត់ ៖ គាត់ជាមេគុក ។

ដារ៉ា ៖ មានអនុមានអីដែរ?

សំផាត់ ៖ មិនដឹងជាពីណាអនុខ្ញុំអត់ដឹងដែរ ឃើញតែគាត់ម្នាក់ហើយយោធាប្រហែលជា២០ទៅ៣០ នាក់ គ្រាន់ថាអនុប្រធានខ្ញុំមិនដឹងជាអ្នកណា ។

ដារ៉ា ៖ តា សឿន គាត់មានដែលធ្វើដំណើរចេញពីកន្លែងគុកហ្នឹងទេ?

សំផាត់ ៖ ចេញចូលៗ ។

ដារ៉ា ៖ ចេញចូលចឹងតា ពូស្មានគាត់មានទៅណាដែរ?

សំផាត់ ៖ ទេ អារឿងការងារគាត់ ខ្ញុំមិនសូវដឹងដែរ ។

ដារ៉ា ៖ អាចថាចេញមកផ្ទះយាយថែមដែរ?

សំផាត់ ៖ បាទ!ប្រហែលជាមក ។

ដារ៉ា ៖ ប្រហែលឬមួយក៏?

សំផាត់ ៖ ប្រហែលជាមកផ្ទះយាយថែមហ្នឹងហើយ ការងារបើយាយថែមគាត់ប្រធាន គាត់ជាអ្នកបញ្ជា ។

ដារ៉ា ៖ ចឹងពូមានបានធ្លាប់មកជាមួយ តា សឿន មកផ្ទះយាយថែមជាមួយគ្នាហ្នឹងទេ?

សំដាត់ ៖ អត់ទេ គាត់ប្រើមកតែមួងដូចជាខ្ញុំប្រាប់ហ្នឹងណាស់ គាត់ប្រើឲ្យយកម៉ាស៊ីតដូចជាម៉ាស៊ីត ហ្នឹងឯង ។

ដាវ៉ា ៖ ហើយ តា សឿន គាត់ជិះអីពេលចេញពីគុកហ្នឹង?

សំដាត់ ៖ គាត់ជិះម៉ូតូសេអិលហ្នឹងឯង ។

ដាវ៉ា ៖ ម៉ូតូសេអិលដែលពណ៌អី ពណ៌អីរបស់តា សឿន?

សំដាត់ ៖ សេអិល កាលនោះដូចជាមានតែពណ៌សៗ ។

ដានី ៖ ពណ៌សដូចគ្នា ដូចម៉ូតូយាយថែមដែរ?

សំដាត់ ៖ ចុះមានម៉ូតូអីប្លែកអីណា បើមិនជិះម៉ូតូទេ ជិះរទេះសេះពីរមុខ ។

ដាវ៉ា ៖ ចុះយាយថែមគាត់ជិះអី ពិតប្រាកដ?

សំដាត់ ៖ ទេ វាមិនទៀងមិនទាត់ដែរ ជួនកាលរទេះសេះទៅជួនកាលគាត់ម៉ូតូទៅ ។

ដាវ៉ា ៖ គាត់ជិះម៉ូតូភាគច្រើនភាគតិច?

សំដាត់ ៖ ភាគច្រើនទៅឆ្ងាយអី ។

ដាវ៉ា ៖ ហើយចុះតា សឿនមាននិរសាដែរ?

សំដាត់ ៖ មានយោធាហ្នឹងឯង ទៅណាហៅអាណាទៅជាមួយទៅមានអាណានិរសាគាត់ច្បាស់ទេ ។

ដានី ៖ យោធាហ្នឹងសុទ្ធតែប្រុសៗឬមួយមានស្រីដែរ?

សំដាត់ ៖ ប្រុសៗដល់ស្រីៗគេហៅសេនាជនសម័យនោះ ។

ដានី ៖ ចុះផ្ទះតា សឿននៅកន្លែងណា?

សំដាត់ ៖ នៅក្នុងគុក ។

ដានី ៖ ផ្ទះគាត់ម៉ង ផ្ទះតា សឿន ណា?

សំដាត់ ៖ អត់ដឹងទេ នៅហ្នឹងគុកកន្លែងគាត់នៅនិងមាត់ស្រះហ្នឹងតែម្តង ។

ដាវ៉ា ៖ កន្លែងមាត់ស្រះ?

សំដាត់ ៖ បាទ!គាត់ធ្វើផ្ទះនៅហ្នឹង ។

ដានី ៖ គាត់នៅតែម្នាក់ឯងឬប្រពន្ធកូននៅហ្នឹងដែរ?

សំដាត់ ៖ ប្រពន្ធកូនគាត់ ។

ដាវ៉ា ៖ នៅក្នុងបរិវេនគុកហ្នឹងដែរ?

សំដាត់ ៖ បាទ ។

ដាវ៉ា ៖ អត់មាននៅក្រៅបរិវេនគុកហ្នឹងទេចឹង?

សំផាត់ : អត់ទេ ។

ដានី : ពូកាលហ្នឹងប្រពន្ធកូនគាត់ឈ្មោះអីហើយមានកូនប៉ុន្មាននាក់ដែរ?

សំផាត់ : ថា ភ្លេចឈ្មោះប្រពន្ធ ។

ដានី : ពូអាចរកនឹកបន្តិចមើល?

សំផាត់ : រកនឹកប្រពន្ធអត់ឃើញទេ ខ្ញុំរកនឹកតើតែមិនដឹងជាប្រពន្ធគាត់ឈ្មោះស្អី ។

ដានី : គាត់មានកូនប៉ុន្មាននាក់?

សំផាត់ : កាលនោះកូនគាត់មានបីនាក់ ។

ដារ៉ា : ស្រីប្រុស?

សំផាត់ : ស្រីពីរប្រុសមួយ ប្រុសបងគេ ។

ដារ៉ា : កូនធំៗហើយ?

សំផាត់ : កូនតូចអត់មានធំទេ តែអាបងគេប្រហែលជាអាយុចូល៧ទៅ៨ឆ្នាំ ព្រោះមាន“ព” នៅដៃមួយដើរដឹកដៃមួយអាមួយនោះវាដើរខ្លួនវាបាន ។

ដារ៉ា : ចឹងក្រោយមកពូមានដឹងថា តា សឿនហ្នឹងនៅណានៅណីទេ?

សំផាត់ : អត់ទេ ។

ដានី : ប្រហែលពូ?

សំផាត់ : មិនប្រហែលទេ មិនដឹងតែម្តង ។

ដានី : តែពូមានដែលឮគេថាគាត់នៅណាអីទេ មានធ្លាប់ឮ?

សំផាត់ : ឮអត់ច្បាស់! បានជាអត់ថាដឹង វាមិនច្បាស់ថាគាត់នៅណាបើដឹងខ្ញុំទៅលេងគាត់ដែលតែវាអត់ដឹងច្បាស់ដែរ ។

ដារ៉ា : ចឹងបើសិនជាដឹងពូនិងទៅលេងទៀត?

សំផាត់ : ព្រោះគាត់ធ្លាប់ជួយខ្ញុំបានរស់ដែរ ។

ដានី : អាចថាពូប្រហែលជាគាត់នៅណានៅណីទេ...?

សំផាត់ : វាមិនប្រហែលទៀតណាស់ វាមិនប្រហែលថាគាត់នៅចំណុច“ក” នោះវាអត់មាន ។

ដារ៉ា : ដូចថាកាលពីយើងជជែកគ្នាពីខាងដើមមុននោះពូថានៅកន្លែង៤២?

សំផាត់ : គ្រាន់តែគេប្រហែលថា ឈ្មោះ សឿននៅ៤២ ដល់សួរទៅវាអត់មាន ។

ដារ៉ា : ៤២ហ្នឹងកន្លែងណា?

សំផាត់ : ៤២ហ្នឹងជាកន្លែងទាហាន ។

ដានី ៖ កងពល៤២?

សំដាត់ ៖ កងពល៤២ តា វ៉ូយនោះ ។

ដានី ៖ ប៉ែន វ៉ូយហ្នឹង?

សំដាត់ ៖ បាទ!ដល់សួរៗ ទៅថាអត់មានសឿននោះទេ ។

ដានី ៖ មិនមែនសឿនហ្នឹងទេ?

សំដាត់ ៖ បាទ ។

ដានី ៖ ចុះនៅម៉ាឡៃ?

សំដាត់ ៖ នៅម៉ាឡៃខ្លះសួរទៅថានៅម៉ាឡៃ ដល់សួរបញ្ជាក់មែនទែនទៅថាមិនមែនទេ មិនដឹងទេ ។

ដានី ៖ បើពូចាំប្រពន្ធគាត់ហ្នឹងងាយស្រួលរក?

សំដាត់ ៖ អត់ចាំ ។

ដានី ៖ អាចជួយរកនឹកប្រពន្ធគាត់?

សំដាត់ ៖ មិនច្បាស់ចឹងមិនដឹងថាប្រាប់ថានៅណា អត់ដឹងច្បាស់មែន វាអត់ច្បាស់ ។

ដាវ៉ា ៖ តែបើសិនជាពូបានដឹងឈ្មោះប្រពន្ធគាត់ចឹងវាងាយស្រួលបញ្ជាក់បន្ថែមអីចឹងពូ?

សំដាត់ ៖ តែពួកខ្មែរក្រហមវាច្រើននៅចង្កោមវា ។

ដាវ៉ា ៖ វាអាចថានៅអន្លុងវែងដែរ?

សំដាត់ ៖ អន្លុងវែងដូចជាអត់នៅទេ ។

ដានី ៖ ចឹងអត់នៅទេ?

សំដាត់ ៖ បើនៅ នៅអាដូរខាងនេះទេ ដូរខាងលិចនេះ ។

ដានី ៖ ខាងលិចខាងណា?

សំដាត់ ៖ ដូរម៉ាឡៃអី ។

ដាវ៉ា ៖ ដូរម៉ាឡៃវិញ?

សំដាត់ ៖ បាទ ។

ដាវ៉ា ៖ បើសិនជានៅរស់គាត់អាយុប្រហែលជាប៉ុន្មាន?

សំដាត់ ៖ ទេ អាយុបើថា ៧០ក៏កន្លុយធំដែរ ។

ដាវ៉ា ៖ ចឹងបើ៧០ក៏កន្លុយធំទៀត?

សំដាត់ ៖ បាទ ។

ដាវ៉ា ៖ សម្បុរសំបកកំពស់កំពគាត់យ៉ាងម៉េចដែរ?

សំដាត់ ៖ គាត់រាងមាំ ...មានរោមដាប់នេះ ។

ដារ៉ា ៖ ពុកមាត់?

សំដាត់ ៖ បាទ!ពុកមាត់ពេញទាំងអស់ ។

ដានី ៖ ពេញមុខតែម្ដងពូ?

សំដាត់ ៖ បាទ! កោរហូតហ្នុង ។

ដារ៉ា ៖ មើលមុខគាត់ទំនងជាកាចឬស្លូតពូ?

សំដាត់ ៖ យី!កាចៗ ។

ដារ៉ា ៖ កាច?

សំដាត់ ៖ បាទ ។

ដារ៉ា ៖ សម្លេងគាត់យ៉ាងម៉េចទៅ?

សំដាត់ ៖ សម្លេងរូសរ៉ាស ។

ដារ៉ា ៖ ចឹងបានជាគេឲ្យមកធ្វើជាប្រធានគុក?

សំដាត់ ៖ ឲ្យធ្វើ ទេខ្ញុំដែលដឹង ។

ដានី ៖ គាត់មានសក់យ៉ាងម៉េច?

សំដាត់ ៖ សក់គាត់រាងឈ ។

ដានី ៖ សក់ឈមិនមែនសក់រួញអីទេ?

សំដាត់ ៖ អត់ទេ ។

ដានី ៖ សម្បុរ?

សំដាត់ ៖ ជ្រះ ។

ដានី ៖ សម្បុរស?

សំដាត់ ៖ បាទ!តាមប្រពន្ធគាត់ប្រាប់ខ្ញុំម្ដងថា គាត់ធ្វើគ្រូ ។

ដារ៉ា ៖ គាត់ធ្វើគ្រូ?

សំដាត់ ៖ ធ្វើគ្រូបង្រៀន ។

ដារ៉ា ៖ គ្រូបង្រៀនទៀត?

សំដាត់ ៖ បាទ ។

ដានី ៖ ចុះគាត់ជាអ្នកស្រុកណា?

សំផាត់ ៖ អារឿងស្រុកខ្ញុំអត់ដឹងទេ គ្រាន់តែដឹងថាគាត់ជាគ្រូបង្រៀននៅភ្នំពេញមុនខ្មែរក្រហមចូល គាត់ជាគ្រូបង្រៀន ព្រោះខ្ញុំសង្កេតមើលគាត់សរសេរអីមិនសូវជាឈ្វោកប៉ុន្មានទេ សរសេរធម្មតា មើលទៅនេះទៅនោះគាត់សរសេរបាន ។

ដានី ៖ បាទ!ចុះលោកពូជឿអត់ យាយថែមថាគាត់អត់ដែលស្គាល់គុកភ្នំទ្រយោង?

សំផាត់ ៖ ទេ!បើគាត់ឆ្លើយបដិសេធថាគាត់មិនដែលស្គាល់ហើយ មិនដឹងអ្នកណាស្គាល់ទៀតទេ ។

ដានី ៖ បានន័យថាយ៉ាងម៉េច?

សំផាត់ ៖ ទេ បើគាត់ជាគណៈស្រុកហើយគាត់មិនស្គាល់ភ្នំទ្រយោងឲ្យពីណាទៅស្គាល់ជំនួសគាត់ទៀត បើគាត់ជាមេគុកដែលនោះ ។

ដានី ៖ គាត់ជាមេគុកដែរ?

សំផាត់ ៖ គាត់បញ្ញាតា សឿនហ្នឹងឯង ។

ដារ៉ា ៖ ហើយពូធ្លាប់ឃើញថា យាយថែមនៅកន្លែងគុកហ្នឹងទៀត?

សំផាត់ ៖ ទៅម្តង! ប្តីគាត់ទៅម្តង ខ្ញុំចាំបានប្តីគាត់ទៅម្តងដែរ ។

ដារ៉ា ៖ ប្តីគាត់ឈ្មោះអី?

សំផាត់ ៖ ប្តីគាត់ឈ្មោះ តា ញ៉ែន ប្តីគាត់តូចក្រញ៉េះៗ ។

ដានី ៖ ប្តីគាត់ធ្វើអី ឋានៈអី?

សំផាត់ ៖ ប្តីគាត់កាលនោះ គាត់នៅចៅហ្វាយស្រុកស៊ីសាផុនហ្នឹងដែរ ។

ដារ៉ា ៖ គាត់ទៅជាមួយប្តីគាត់ឬមួយយ៉ាងម៉េច?

សំផាត់ ៖ កាលនោះគាត់ទៅគ្នាគាត់៤ទៅ៥នាក់ សុទ្ធតែយោធា ។

ដារ៉ា ៖ ទៅធ្វើអីកាលហ្នឹង?

សំផាត់ ៖ ទៅលេង ។

ដារ៉ា ៖ ទៅលេងទេ?

សំផាត់ ៖ ទៅលេងតា សឿន មិនដឹងថាគេលែងរឿងអីខ្ញុំអត់នៅជិតដែរ គ្រាន់តែឃើញ សួរគេទៅថានេះអីប្តីយាយថែម!

ដានី ៖ កាលហ្នឹងយាយថែមគាត់មានកូនចៅប៉ុន្មាននាក់?

សំផាត់ ៖ ខ្ញុំមិនដឹងថាកូនចៅគាត់ប៉ុន្មាននាក់ទេ ។

ដារ៉ា ៖ គាត់មានកូនទេ កាលនៅកន្លែងហ្នឹង?

សំផាត់ ៖ មានហើយ ។

ដារ៉ា ៖ កាលនៅភ្នំលៀបគាត់មានកូនទេ?

សំផាត់ ៖ មាន!

ដារ៉ា ៖ ស្រីប្រុសកាលហ្នឹង?

សំផាត់ ៖ តែឃើញអាកូនប្រុសមួយនោះស្រីៗប៉ុន្មាននាក់ទៀតខ្ញុំអត់ដឹងទេ ។

ដានី ៖ ពូមានចាំថាពេលដែលគាត់ទៅកន្លែងគុកអី កាលហ្នឹងគាត់មានផ្ទៃពោះឬក៏យ៉ាងម៉េច ឬក៏គាត់មានកូនខ្ចីអី?

សំផាត់ ៖ យាយថែមកាលនោះដូចជាពោះធំ មុនវៀតណាមចូល មើលដែលទៅគាត់មានកូនហ្នឹងដែលចេញទៅ ។

ដានី ៖ ចេញទៅណា?

សំផាត់ ៖ ចេញទៅ ពេលវៀតណាមចូលមកមិនរត់ ។

ដានី ៖ បាទ ។

សំផាត់ ៖ គាត់គាត់មានកូនហ្នឹង ។

ដានី ៖ ចឹងកាលទៅគុកហ្នឹងគាត់មានកូនហ្នឹងឬក៏គាត់នៅពោះធំ?

សំផាត់ ៖ ដូចជានៅពោះធំទេ ។

ដារ៉ា ៖ ពេលគាត់ទៅកន្លែងគុកហ្នឹងទៅជួបតា សឿនហ្នឹង?

សំផាត់ ៖ កាលទៅជួបហ្នឹងដូចនៅពោះធំទេ មិនទាន់សម្រាលកូនទេ វាក្មេចវាមិនដឹងថាគាត់សម្រាលកូនមុនឬក៏វៀតណាមជិតចូលគាត់សម្រាលកូនទេ ដូចថាមុនពីរបីខែព្រោះថាក្មេចដែរវាយូ ។

ដានី ៖ ពេលវៀតណាមចូលទៅគាត់មានកូនហ្នឹង កូនហ្នឹងប៉ុណ្ណា?

សំផាត់ ៖ កូនហ្នឹងនៅតូចដែលហ្នឹង ។

ដានី ៖ ចឹងមួយទៀតឈ្មោះ តា កាន់ ដែលគាត់ធ្វើគណៈឃុំភ្នំលៀបហ្នឹង តា កាន់ តា កាន់ពូស្គាល់គ្រួសារគាត់ដូចប្ដីជាប្ដីប្រពន្ធគាត់?

សំផាត់ ៖ ស្គាល់តែតា កាន់ហ្នឹងឯង ខ្ញុំស្គាល់ មិនមែនថាទៅប្រូកាទិ ឬក៏ស្គាល់ជិតជិតណាស់ណាទេស្គាល់ធម្មតាហ្នឹងឯង ។

ដានី ៖ ស្គាល់ធម្មតាទេ តែគាត់នៅរស់ទេ សព្វថ្ងៃ?

សំផាត់ ៖ អត់ដឹងដែរ ។

ដានី ៖ អត់ដែលឮដំណឹងថាគាត់នៅណា?

សំដាត់ ៖ អត់ដឹងទេ ។

ដារ៉ា ៖ ចុងក្រោយពូថាខាងតុលាការគេមកជួបពូ មកជួបសួរនាំពូណា ដែលខាងតុលាការមកជួបពូ ពូបាននិយាយដូចដែលពូបាននិយាយប្រាប់ខាងខ្ញុំដែរអត់?

សំដាត់ ៖ អត់មានដែលពីណាមកសួរខ្ញុំផង ។

ដារ៉ា ៖ ប៉ុន្មានថ្ងៃមុននោះដូចថាមកតាមរយៈ?

សំដាត់ ៖ មកឡាននោះ ។

ដារ៉ា ៖ បាទ មកឡានហ្នឹង ។

សំដាត់ ៖ គ្រាន់តែសួរចង់ដឹងថា តា សឿនទៅកន្លែងណាហ្នឹងឯង ។

ដារ៉ា ៖ សួរតែប៉ុន្មានម៉ាត់ហ្នឹង?

សំដាត់ ៖ បាទ ។

ដានី ៖ គេអត់មានមកសួរនាំអីដូចពួកខ្ញុំសួរចឹងទេ?

សំដាត់ ៖ អត់ទេ សួរចង់ដឹងរកតែតា សឿនខ្ញុំថាខ្ញុំអត់ដឹងទេ ។

ដារ៉ា ៖ ចឹងកាលសួរហ្នឹងមានកត់ត្រាអីដែលពូ?

សំដាត់ ៖ អត់ទេ សួរធម្មតា ។

ដារ៉ា ៖ សួរធម្មតាទេ?

សំដាត់ ៖ សួរនិយាយគ្នាលេងធម្មតា ។

ដារ៉ា ៖ ចឹងទេ អត់មានសម្ភាសជាកត់ត្រាឲ្យលិខិតអីឲ្យទៅពូវិញមានផ្តិតមេដៃអីអត់ទេ?

សំដាត់ ៖ អត់ទេ គ្រាន់សាកសួររកចង់ហៅទៅកន្លែងផ្ទះសំណាក់ ។

ដារ៉ា ៖ អ ៗ!

សំដាត់ ៖ស្រាប់តែព្រឹកឡើងបាត់ទៅ ។

ដារ៉ា ៖ ចឹង?

សំដាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងកាលហ្នឹងចង់អញ្ជើញពូទៅកន្លែងផ្ទះសំណាក់ដើម្បីសួរនាំដែរ?

សំដាត់ ៖ បាទ ។

ដារ៉ា ៖ តែមិនបានអញ្ជើញទៅទេ?

សំដាត់ ៖ អត់បានទៅទេ ។

ដារ៉ា ៖ យ៉ាងម៉េចចឹង?

សំផាត់ : អត់ដឹងផង ។

ដារ៉ា : កាលហ្នឹងមកគ្នាប៉ុន្មាននាក់?

សំផាត់ : មកគ្នាពីរនាក់ ឡានមួយ ។

ដារ៉ា : តែពីរនាក់ទេ?

សំផាត់ : បាទ ។

ដារ៉ា : មានខ្មែរមានបរទេស?

សំផាត់ : ខ្មែរទាំងអស់ ។

ដារ៉ា : ខ្មែរទាំងពីរនាក់ហ្នឹង?

សំផាត់ : បាទ ។

ដារ៉ា : អត់មានបរទេសទេ?

សំផាត់ : អត់ទេ គ្រាន់តែគេប្រាប់ថា គេនៅសាលាក្តីខ្មែរក្រហមហ្នឹង ។

ដារ៉ា : គេប្រាប់ចឹង?

សំផាត់ : បាទ ។

ដារ៉ា : មកដល់ម៉េចបានជាដឹងឈ្មោះពូពេលដែលមកដល់ មកដល់សួរនាំពីណាខ្លះ?

សំផាត់ : មកដល់ខ្ញុំសួរថាចេះ ម៉េចបានដឹងថាខ្ញុំនៅនេះ ថាដឹងសួរប៉ូលីស សួរឃាយណាន់ ហ្នឹង ឯង ។

ដារ៉ា : បាទ ។

សំផាត់ : បានដឹងលេខទូរសព្ទគេមករក ។

ដារ៉ា : ពេលគេមករកមកដល់បានជួបពូ?

សំផាត់ : បាទ ។

ដារ៉ា : បានជួបពូទៅគេមកគ្នាពីរនាក់?

សំផាត់ : គ្នាពីរនាក់ ។

ដារ៉ា : ហើយប្រាប់ថាមកពីតុលាការខ្មែរក្រហម?

សំផាត់ : បាទ!គេជាអ្នកស្រាវជ្រាវ ។

ដានី : ស្រាវជ្រាវ កាលហ្នឹងពូចាំឈ្មោះទេខ្មែរពីរនាក់ហ្នឹងមានប្រាប់ឈ្មោះពូទេ?

សំផាត់ : ទេ គេដូចជាមិនព្រមប្រាប់ឈ្មោះចេះឈ្មោះចុះអីអត់មានប្រាប់ទេ គ្រាន់តែមកសាកសួរពីរឿងថាមានដឹងអាស័យដ្ឋានគា សឿនអីដែរ ហីខ្ញុំថា ខ្ញុំអត់ដឹងដែរ ។

ដារ៉ា ៖ សួរតែប៉ុណ្ណឹងអត់មានសួរអីទៀតទេ?

សំផាត់ ៖ អត់ទេ គេនិយាយចុងក្រោយគេមានតែនិយាយចេះថា កុំទៅនិយាយប្រាប់គេថាខ្ញុំមកសាកសួរអីពួដល់តុលាការពួអី ខ្ញុំឈប់និយាយតែម្តង តែមិនដឹងថាគេមកធ្វើអីខ្ញុំមិនដឹងផង ។

ដារ៉ា ៖ ចឹងគ្រាន់តែមកសាកសួរប៉ុណ្ណឹង?

សំផាត់ ៖ គ្រាន់មកសាកសួរប៉ុណ្ណឹងកុំពិបាកឲ្យពួទៅឆ្ងាយអី ។

ដារ៉ា ៖ ចុះថាម៉េច ការដែលណាត់ពូទៅផ្ទះសំណាក់អីនោះ គេថាយ៉ាងម៉េចគេចង់ណាត់ពូ?

សំផាត់ ៖ សួរខ្ញុំថាទៅបានទេនៅផ្ទះសំណាក់ ខ្ញុំសួរថាទៅរយៈពេលប៉ុន្មានម៉ោងល្ងាចចេះ ថាប្រហែលជាពីរម៉ោងចប់ ខ្ញុំថាពីរម៉ោង ម៉ោងប៉ុននេះហើយ ម៉ោង១០ ។

ដារ៉ា ៖ កាលមកហ្នឹងមកប្រហែលជាម៉ោងប៉ុន្មានពូ?

សំផាត់ ៖ មកប្រហែលជាម៉ោង៨ ។

ដារ៉ា ៖ ម៉ោង៨យប់ហ្នឹង?

សំផាត់ ៖ បាទ!នៅនេះម៉ោង៨យប់នៅធម្មតាមានគេមកទិញមកដូរអី ។

ដារ៉ា ៖ មានភ្លើងអីធម្មតាតែម៉ោង៨?

សំផាត់ ៖ បាទ!មកម៉ោង៨ ។

ដារ៉ា ៖ ចង់អញ្ជើញពូទៅកន្លែងផ្ទះសំណាក់ហ្នឹងម៉ោង៨ហើយត្រូវចំណាយពេលពីរម៉ោងទៀត?

សំផាត់ ៖ ពីរម៉ោង ម៉ោង១០ជាងបាត់ហើយ ។

ដារ៉ា ៖ ម៉ោង១០ជាង?

សំផាត់ ៖ ខ្ញុំថាចាំព្រឹកទៅ ខ្ញុំរៀបដេកហើយ ។

ដារ៉ា ៖ ពូថាចាំព្រឹក?

សំផាត់ ៖ បាទ!ចង់ឲ្យខ្ញុំជូនទៅម៉ាឡៃ ខ្ញុំថាខ្ញុំមិនដឹងទេ ចាំមើលព្រឹកសិនទៅ ព្រោះខ្ញុំអត់ស្គាល់មិនថាទៅរកយ៉ាងម៉េច ។

ដានី ៖ ចឹងគាត់ចង់ឲ្យជូនទៅម៉ាឡៃ?

សំផាត់ ៖ បាទ ។

ដារ៉ា ៖ ចឹងដល់ពេលព្រឹកឡើងពូអត់បានជួបទេ?

សំផាត់ ៖ អត់ទេ ។

ដារ៉ា ៖ ហើយគេអត់បានមកជួបពូ?

សំផាត់ ៖ អត់ឃើញមកទេ ។

ដារ៉ា ៖ បាត់ត្រឹមប៉ុណ្ណឹងទៅ?

សំផាត់ ៖ បាទ!ខ្ញុំមិនដឹងដែរ គាត់ខាងអី តែ គប្រាប់ខ្ញុំថាគាត់នៅកន្លែងស្រាវជ្រាវខាងតុលាការខ្មែរក្រហម ។

ដារ៉ា ៖ ចឹងខ្មែរទាំងពីរនាក់?

ដារ៉ា ៖ ខ្មែរទាំងពីរនាក់?

សំផាត់ ៖ បាទ! ខ្ញុំពូប្អូនខ្ញុំគេទៅប្រាប់ដែរថាមានគេទៅជួបដល់នោះឯង សួរកន្លែងប៉ូលីសណា ប្អូនខ្ញុំនៅកន្លែងប៉ូលីស ដល់គេស្គាល់លេខទូរស័ព្ទ ។

ដារ៉ា ៖ ចុះគេជិះមកហ្នឹងឡានអីគេ?

សំផាត់ ៖ ឡានដូចឡានលុចស៊ីសអាធំ ។

ដារ៉ា ៖ ពណ៌អីគេ?

សំផាត់ ៖ ដូចជាពណ៌ពងមាន់ ។

ដារ៉ា ៖ មិនមែនឡានពណ៌សរមានស្លាកតុលាការទេ?

សំផាត់ ៖ ទេ ដូចមិនមែនទេ ។

ដារ៉ា ៖ ឡានមកចតនៅមុខហ្នឹង?

សំផាត់ ៖ ចតនៅមុខហ្នឹងឯង ។

ដារ៉ា ៖ អត់មានស្លាកតុលាការទេ?

សំផាត់ ៖ ទេ ដូចជាមិនមែន ខ្ញុំមិនបានមើលអីផង ផ្លាក់លេខ ផ្លាក់អី គ្រាន់តែដឹងថា ណុះគេតេមកប្រាប់ថា គេមកសួររក ចង់សួររក តាសឿន ។

ដារ៉ា ៖ គេមកពីព្រះនេត្រព្រះហ្នឹងហ្អី?

សំផាត់ ៖ បាទ!គេមកពីនោះ ។ អីចឹងអត់មានអ្នកមកពីណោះទេ?

ដារ៉ា ៖ ខ្ញុំអត់ដឹងច្បាស់ថាមានអ្នកមកឬមិនមកទេណាពូ តែគ្រាន់តែថាតាមរយៈ យាយណាន់ហ្អស! យាយណាន់គាត់ថាពូបានខលទៅជួបសួរនាំគាត់វិញថាតុលាការគេសួរនាំរឿងអីទៅ យាយណាន់ អីចឹងណាពូ ដើម្បីឲ្យពូបានដឹងពត៌មានមុនអីចឹងទៅណា ហើយខ្ញុំមិនដឹងថាតុលាការបាន ជួបពូឬមិនបានជួបពូអីទេ ។ អីចឹងទើបតែថ្ងៃនេះទេដែលពូជិរាបប្រាប់ខ្ញុំថាតុលាការគេមកជួបពូតែគេអត់បានសួរនាំអី?

សំផាត់ ៖ ទេ!ខ្ញុំមិនដឹងថាយតុលាការឬមិនតុលាការអីទេគេគ្រាន់តែប្រាប់ខ្ញុំថាគេនៅខាងសាលាក្តីខ្មែរក្រហម ។

ដារ៉ា ៖ គេថាអីចឹង?

សំផាត់ ៖ បាទ! ពួកក្រុមស្រាវជ្រាវ ។

ដារ៉ា ៖ ព្រោះពូ បើសិនជាតុលាការគេចុះមកមែនគេមានឡានមានអីច្បាស់លាស់មានស្លាកមានអីណាពូ ។

សំផាត់ ៖ ខ្ញុំអត់បានមើលស្លាកផង ។

ដារ៉ា ៖ ព្រោះអីភាគច្រើនឡាននៅតុលាការពណ៌សរដូចឡានឡង់គ្រីស័រយើងចឹងណា ពណ៌សអី ចឹងតែគេមានផ្លាកតុលាការ ។

សំផាត់ ៖ អត់បានមើលស្លាកផង ។

ដារ៉ា ៖ តែដល់ពេលពណ៌ឡាន?

សំផាត់ ៖ ដូចជាពណ៌ពងមាន់ ។

ដារ៉ា ៖ ពណ៌ពងមាន់ទេ ហើយឡានហ្នឹងម៉ាកអីគេពូ?

សំផាត់ ៖ ដូចជាលុចស៊ីសអាធំ ។

ដារ៉ា ៖ លុចស៊ីសទៀត?

សំផាត់ ៖ មិនមែនលុចស៊ីសអាតូចទេ ។ អីចឹងផ្សេងគ្នា? ខាងតុលាការផ្សេង ខាងស្រាវជ្រាវឯនេះផ្សេង?

ដារ៉ា ៖ បាទ!ផ្សេងគ្នា ស្ថាប័នពីរផ្សេងគ្នាពូ ។ ខាងខ្ញុំនេះមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយើងធ្វើការសំខាន់ គឺចងក្រងប្រមែប្រមូលចងក្រងឯកសារដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។

សំផាត់ ៖ ខាងនោះគេខាងតុលាការខ្មែរក្រហម?

ដារ៉ា ៖ ខាងនោះគេខាងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយយើងពត៌មានយើងសួរនាំទាំងពត៌មានប្រវត្តិសាស្រ្ត ទាំងពត៌មានខក្រិដ្ឋកម្មអីហើយបើខាងតុលាការគេអាចយកទៅប្រើប្រាស់បានគេយកទៅណាពូ ហើយបើប្រើប្រាស់មិនបានយើងទុកប្រើប្រាស់ខាងប្រវត្តិសាស្រ្តរបស់យើង ។

សំផាត់ ៖ អីចឹងប្រហែលពួកខាងតុលាការហ្នឹងមែន ព្រោះមិនមែនមកសួរអីចឹងទេគ្រាន់តែសួររកថាទីលំនៅស្ថានរបស់ គាសឿន ខ្ញុំថាមិនស្គាល់ក៏ចប់ប៉ុណ្ណឹងមក គោលដៅគេចង់ដឹងតែគាសឿន នៅទីណាឲ្យច្បាស់ ។

ដារ៉ា ៖ អត់មានមកសួរនាំរឿង?

សំផាត់ ៖ អត់ទេ!អត់មានអីចឹងទេ ។

ដារ៉ា ៖ អត់មានសួរនាំរឿងពូជាប់គុកនៅភ្នំទ្រយ៉ូងអីទេ?

សំផាត់ ៖ អត់ទេ! គ្រាន់តែដឹងថាខ្ញុំធ្លាប់ជាប់គុក ។

ដារ៉ា ៖ គេដឹងដែរ?

សំផាត់ ៖ គេសួរអីណោះណា! ហីធ្លាប់ជាប់គុក ហីថាខ្ញុំធ្លាប់ស្គាល់ តាសឿន ច្បាស់ ។ ដល់មកសួរខ្ញុំថាស្គាល់ច្បាស់ហ្នឹង គាត់នៅកន្លែងណាសព្វថ្ងៃ? ដល់ខ្ញុំឆ្លើយថាមិនដឹងទៅចប់ ។

ដារ៉ា ៖ អីចឹងពីមុនមកបានន័យថាគេសួរពីឃុំនៅព្រះនេត្រព្រះមកដឹងថាពូធ្លាប់ជាប់គុកនៅភ្នំទ្រយ៉ូងដែរ?

សំផាត់ ៖ បាទ!

ដារ៉ា ៖ តែមកដល់អត់មានបានសួរនាំពូពីរឿងពូជាប់គុកយ៉ាងម៉េចអីយ៉ាងម៉េចទេហ្អីពូ?

សំផាត់ ៖ អត់ទេ ។

ដារ៉ា ៖ សួរសំដៅរកតែ តាសឿន ទេ?

សំផាត់ ៖ បាទ!សួរគោលដៅរកតែ តាសឿន មួយទេ ។

ដារ៉ា ៖ អីចឹងខ្ញុំយល់ហើយពូ ហើយអត់មានបផ្ដាំញសំបុត្រស្នាមអីទេ?

សំផាត់ ៖ ទេ អត់មានទេ ។

ដារ៉ា ៖ ហើយចុងក្រោយក៏អត់បានមកជួបពូដែរ អត់បានមកសួរនាំពូរឿងជាប់គុកនៅភ្នំទ្រយ៉ូងទេ?

សំផាត់ ៖ អត់ទេ ។

ដារ៉ា ៖ ខ្ញុំអគុណពូច្រើន ហើយដែលពូបានផ្ដល់ពត៏មានហើយអត់ចង់រំខានពេលវេលាពូច្រើនទៀតទេអីចឹងពួកខ្ញុំសូមអគុណពូច្រើនណាពូ ។

សំផាត់ ៖ បាទ!

«ចប់»